ព្រឹត្តិបត្រព័ត៌មានលេខ ០៩
(តុលា - ធ្នូ ២០២៣)

Newsletter Issue 09
(October - December 2023)

នៅក្នុងលេខនេះ | In this Issue

- កិច្ចសម្ភាសន៍ជាមួយអគ្គនាយកនៃធនាគារ ហ្វីលីព
  Interview with CEO of Phillip Bank
- បទពិសោធន៍របស់លោកស្រី ខៀវ ធិតា ស្ថាបនិក SOGE Green Solar Energy Cambodia ដែលទទួលបានកម្ចីដែលមានការធានាពី CGCC
  Meet with Ms. Kheav Thida, Founder of SOGE Green Solar Energy Cambodia Who Received a Credit Guarantee from CGCC
- អត្ថបទស្វែងយល់ពីការធានាលើសញ្ញាប័ណ្ណរបស់ CGCC
  Understanding CGCC's Bond Guarantee

មាតិកា | Contents

សេចក្តីផ្តើម | Introduction ---------- 02
វឌ្ឍនភាពការធានាឥណទាន | Credit Guarantee Progress ---------- 08
កិច្ចសហប្រតិបត្តិការ និងសកម្មភាពនានា | Cooperation and Activities ---------- 13
ការស្វែងយល់អំពីការធានាឥណទាន | Understanding Credit Guarantee ---------- 19
ដៃគូរបស់យើង | Our Partners ---------- 27

ក្រុមការងារកែច្នៃបត្រព័ត៌មាន | Newsletter Editorial Team

រៀបរៀងដោយ | Prepared by:

លោក ណូ លីដា Mr. No Lida	អគ្គនាយករង Deputy Chief Executive Officer
លោកស្រី ពិន ម៉ានីកា Ms. Pin Manika	ប្រធានការិយាល័យទីផ្សារ និងអភិវឌ្ឍន៍អាជីវកម្ម Manager of Marketing and Business Development
លោកស្រី សន ឆវីវតី Ms. Sorn Chhorvyvatey	អនុប្រធានការិយាល័យទីផ្សារ និងអភិវឌ្ឍន៍អាជីវកម្ម Deputy Manager of Marketing and Business Development
លោក សែ គឹមវាសនា Mr. Se Kimveasna	បុគ្គលិកជំនាញជាន់ខ្ពស់ផ្នែកទីផ្សារ និងទំនាក់ទំនង Senior Executive of Marketing and Communication
លោក គឹម ហេងបំណង Mr. Kim Hengbomnorng	បុគ្គលិកជំនាញជាន់ខ្ពស់ផ្នែកទីផ្សារ និងយុទ្ធនាការ Senior Executive of Marketing & Campaign
លោកស្រី សុខ ចរិយា Ms. Sok Chakriya	បុគ្គលិកជំនាញជាន់ខ្ពស់ផ្នែកទំនាក់ទំនង Senior Executive of Relationship Management

ចូលរួមផ្តល់មាតិកាដោយ | Contributed Contents by:

លោក ប៉ុក សូសត្យា Mr. Pok Sosathya	បុគ្គលិកជំនាញជាន់ខ្ពស់ផ្នែកប្រតិបត្តិការ Senior Executive, Credit Administration
លោក គី ហុង Mr. Ky Hong	បុគ្គលិកជំនាញផ្នែកអភិវឌ្ឍផលិតផល Executive of Product Development

រចនាដោយ | Designed by:

លោក នង សុគន្ធា Mr. Nong Sokunthea	បុគ្គលិកជំនាញជាន់ខ្ពស់ផ្នែកមាតិកា និងរចនាក្រាហ្វិក Senior Executive of Creative Contents and Graphic Designer

ត្រួតពិនិត្យដោយ | Reviewed by:

លោក **KL Wong** Mr. KL Wong	អគ្គនាយក Chief Executive Officer

សេចក្តីផ្តើម | Introduction

សាររបស់អគ្គនាយក | Message from CEO

In the last quarter of 2023, we emphasized mainly on capacity building for both CGCC and our outreach to MSMEs. At the end of November, CGCC team led by H.E. Dr Mey Vann, Secretary of State of the Ministry of Economy and Finance and Chairman of Board Risk Management of CGCC signed a MoU with the Thai Credit Guarantee Corporation (TCG) to establish cooperation between the two corporations to support the development of CGCC with information and knowledge exchange, technical assistance and consultations. TCG has more than 30 years of experience in providing credit guarantees in Thailand. The team also had the opportunity to make a courtesy visit at Kasikorn Bank (KBank), Bangkok which is the head office of one of our PFI, the KBank branch in Phnom Penh.

Korea Credit Guarantee Fund (KODIT) organized a study program on "SME Finance and Support Measures in Korea" and invited staff from CGCC and the Ministry of Economy and Finance to participate. The training covered institutional framework, laws and regulations, credit guarantee schemes and risk management measures. This program is part of our collaboration with KODIT on the exchange of knowledge and learnings from KODIT. It is our first step in developing our institutional regulatory framework with laws and regulations for CGCC.

We visited PFIs at Kratie, Steung Treng, Ratanakiri and Mondulkiri provinces and organized a seminar on "Guaranteed Loans to support the Development of SMEs" in Kratie. We invited SMEs and PFI staff from the respective provinces to share about CGCC and the benefits of guaranteed loans to support the financial needs of SMEs.

In late December, we achieved a significant milestone in our journey towards becoming the local Bond Guarantor. The Rating Agency of Cambodia (RAC) awarded the highest local rating of **khAAA** with a stable outlook. This accomplishment marks a key moment for CGCC, as it positions us to commence guaranteeing corporate bonds from 2024 onwards. This strategic step will enable us to play a vital role in developing the capital market by supporting larger SMEs seeking to raise funds through bonds listed on the CSX.

Looking ahead to 2024, I am optimistic about the opportunities that await us in the coming year. We will continue to build on our successes, reinforce our partnerships, and explore innovative ways to better serve the MSME community. I extend my heartfelt gratitude to each member of our team for your unwavering commitment. Your dedication has shaped the progress of CGCC and I'm confident that together, we will achieve even greater milestones in the years ahead.

Yours sincerely,
KL Wong
CEO

RAC Ratings

Issuer Credit Rating of
Credit Guarantee Corporation of Cambodia

khAAA
Outlook: Stable

Rating Agency of (Cambodia) Plc.
Rating Date: December 19th, 2023
Rating No: 006/23

អំពី ស.ធ.ក. | About CGCC

សាជីវកម្មធានាឥណទានកម្ពុជា(ស.ធ.ក.)គឺជាសហគ្រាសសាធារណៈដែលត្រូវបានបង្កើតឡើងដោយអនុក្រឹត្យលេខ១៤០អនក្រ.បក ចុះថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០២០។ **ស.ធ.ក.** ស្ថិតនៅក្រោមអាណាព្យាបាលបច្ចេកទេស និងហិរញ្ញវត្ថុ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ស.ធ.ក. ត្រូវបានចុះបញ្ជីជាផ្លូវការនៅថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០២០ និងទទួលបានការគាំទ្របច្ចេកទេសពីដៃគូអភិវឌ្ឍន៍មួយចំនួនដូចជា ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ធនាគារពិភពលោក (WB) និងមូលនិធិអភិវឌ្ឍន៍ទុនរបស់អង្គការសហប្រជាជាតិ (UNCDF)។ **ស.ធ.ក.** បានដាក់ឱ្យដំណើរការនូវគម្រោងធានាឥណទានដំបូងនាថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២១។

Credit Guarantee Corporation of Cambodia (CGCC) is a state-owned enterprise established by a Sub-Decree No. 140 ANKR.BK dated 01 September 2020. CGCC is operated under the technical and financial guidance of the Ministry of Economy and Finance (MEF).

CGCC was incorporated on 03 November 2020 and has been receiving technical support from Asian Development Bank (ADB), World Bank, and UN Capital Development Fund (UNCDF). CGCC launched the first guarantee scheme on 29 March 2021”

ទស្សនវិស័យ | Vision

ក្លាយខ្លួនទៅជាស្ថាប័នធានាឥណទាននាំមុខគេនៅប្រទេសកម្ពុជា ក្នុងការបង្កើនបរិយាបន្នហិរញ្ញវត្ថុ និងអភិវឌ្ឍសហគ្រាសខ្នាតតូច និងមធ្យម។

To be the preferred credit guarantee institution in Cambodia to improve financial inclusion and develop the growth of SMEs.

បេសកកម្ម | Mission

ផ្តល់ការធានាឥណទានលើកម្ចីដែលផ្តល់ឱ្យអាជីវកម្ម ដើម្បីចែករំលែកហានិភ័យជាមួយស្ថាប័នផ្តល់កម្ចី និងបង្កើនបរិយាបន្នហិរញ្ញវត្ថុ។

To provide credit guarantees to lenders on loans made to businesses based on international standards to share the risk with lenders and to improve financial inclusion.

គុណតម្លៃនៃ សាជីវកម្មធានាឥណទានកម្ពុជា | Core Values of CGCC

Core Values	Statements	គុណតម្លៃ	សេចក្ដីថ្លែង
TRUSTWORTHY	We are trustworthy by being professional and honest with high integrity.	ទំនុកចិត្ត	ពួកយើងឱ្យតម្លៃលើទំនុកចិត្ត តាមរយៈការបំពេញការងារដោយវិជ្ជាជីវៈ ភាពស្មោះត្រង់ និងភាពសុចរិតខ្ពស់។
RESPONSIBLE	We are responsible by being accountable for our actions and committed to performing our duties with high standards.	ទំនួលខុសត្រូវ	ពួកយើងឱ្យតម្លៃលើទំនួលខុសត្រូវ តាមរយៈការបំពេញការងារប្រកបដោយគណនេយ្យភាព និងការប្តេជ្ញាអនុវត្តភារកិច្ចរបស់ពួកយើង ប្រកបដោយស្តង់ដារខ្ពស់។
UNITED	We are united by being respectful, supportive, and understanding to foster teamwork, diversity, synergy, and cooperation.	សាមគ្គីភាព	ពួកយើងឱ្យតម្លៃលើសាមគ្គីភាព តាមរយៈការគោរព ការគាំទ្រ និងការស្វែងយល់គ្នាទៅវិញទៅមក ដើម្បីជំរុញស្មារតីការងារជាក្រុម ពិពិធភាព សហថាមភាព និងកិច្ចសហប្រតិបត្តិការ។
SUSTAINABLE	We are sustainable by embracing innovation and capacity development to promote inclusive and sustainable growth.	ចីរភាព	ពួកយើងឱ្យតម្លៃលើចីរភាព តាមរយៈការប្រកាន់ភ្ជាប់នូវស្មារតីនវានុត្តន៍ និងការអភិវឌ្ឍសមត្ថភាពជាប្រចាំ ដើម្បីលើកកម្ពស់កំណើនប្រកបដោយចីរភាព និងបរិយាបន្ន។
TRANSPARENT	We are transparent in conducting our work based on a fair, open, ethical, and disciplined manner.	តម្លាភាព	ពួកយើងឱ្យតម្លៃលើតម្លាភាពតាមរយៈការបំពេញការងារ ដោយប្រកាន់ភ្ជាប់ភាពយុត្តិធម៌ ភាពបើកជំហរ ក្រមសីលធម៌ និងវិន័យ។
STATE POLICY-ORIENTED	We are policy-oriented by prioritizing our work to be aligned with the Government/State policies to support socioeconomic growth of Cambodia.	ការគាំទ្រគោលនយោបាយរបស់រាជរដ្ឋាភិបាល	ពួកយើងឱ្យតម្លៃលើការគាំទ្រគោលនយោបាយរបស់រាជរដ្ឋាភិបាល តាមរយៈការកំណត់អាទិភាពការងាររបស់ពួកយើង ឱ្យស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ដើម្បីគាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមរបស់កម្ពុជា។

សមិទ្ធផលសំខាន់ៗ | CGCC's Milestones

១ កញ្ញា ២០២០
ទទួលបានការអនុម័តលើអនុក្រឹត្យស្តីពីការបង្កើតសាជីវកម្ម ធានាឥណទានកម្ពុជា ពីសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី

២ មីនា ២០២១
បានដាក់ឱ្យដំណើរការគម្រោងធានាឥណទានទី១ ហៅថា "គម្រោងធានាឥណទានដើម្បីស្តារអាជីវកម្ម"

២៣ មេសា ២០២១
បានផ្តល់ការធានាឥណទានជាលើកដំបូងលើកម្ចីទំហំ ១លានដុល្លារ

០១ មេសា ២០២២
បានដាក់ឱ្យដំណើរការគម្រោងធានាឥណទានទី៣ ហៅថា "គម្រោងធានាឥណទានសម្រាប់សហគ្រិនស្ត្រី" ដែលមានទំហំទឹកប្រាក់ ៣០លានដុល្លារ

០១ មេសា ២០២២
បានផ្លាស់មកកាន់ការិយាល័យថ្មី ដែលស្ថិតនៅជាន់ទី១៩ នៃមជ្ឈមណ្ឌលអភិវឌ្ឍធុរកិច្ច

២២ សីហា ២០២៣
បានទទួលស្គាល់ពី **SERC** ជាស្ថាប័នធានាលើការបោះផ្សាយសញ្ញាបណ្ណដំបូងគេបង្អស់នៅកម្ពុជា

១៩ ធ្នូ ២០២៣
បានទទួលចំណាត់ថ្នាក់ឥណទាន **khAAA**

៣ វិច្ឆិកា ២០២០
បានចុះបញ្ជីនៅក្រសួងពាណិជ្ជកម្ម

៤ កុម្ភៈ ២០២១
ទទួលបានដើមទុនដំបូងចំនួន ៨១០ប៊ីលានរៀល (សមមូលនឹងប្រមាណ២០០លានដុល្លារ) ពីរាជរដ្ឋាភិបាល

២២ កញ្ញា ២០២១
បានដាក់ឱ្យដំណើរការគម្រោងធានាឥណទានទី២ ហៅថា "គម្រោងធានាឥណទានសម្រាប់សហហិរញ្ញប្បទាន"

៥ វិច្ឆិកា ២០២១
ទទួលបានការលើកលែងអាករលើតម្លៃបន្ថែម (**VAT**) លើកម្រៃធានាឥណទាន

១២ កក្កដា ២០២២
បានដាក់ឱ្យដំណើរការគម្រោងធានាឥណទានសម្រាប់សហហិរញ្ញប្បទានសម្រាប់វិស័យទេសចរណ៍

០១ មករា ២០២៣
ដាក់ឱ្យដំណើរការ "គម្រោងធានាឥណទានជាកញ្ចប់"

ជួបជាមួយបុគ្គលិករបស់ CGCC | Meeting with CGCC's Employee

ខ្ញុំពិតជាមានមោទនភាពដែលបានចូលរួមចំណែកបំពេញបេសកកម្មជាមួយ CGCC ក្នុងការបង្កើនបរិយាបន្នហិរញ្ញវត្ថុ និងគាំទ្រការអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យម នៅកម្ពុជា ដើម្បីបង្កើនការងារ និងប្រាក់ចំណូលជូនប្រជាជនរបស់ប្រទេសរបស់ខ្ញុំ។

លោក ប៉ុក សូសត្យា
បុគ្គលិកជាន់ខ្ពស់ផ្នែកប្រតិបត្តិការ

Mr. Pok Sosathya
Senior Executive,
Credit Administration

KH ដោយមានបទពិសោធន៍ក្នុងវិស័យធនាគារផ្នែកគ្រប់គ្រងហានិភ័យឥណទានកាលពីខែធ្នូ ឆ្នាំ២០២១ ខ្ញុំបានសម្រេចចិត្តផ្លាស់ប្តូរការងារមកជាបុគ្គលិកជាន់ខ្ពស់ផ្នែកប្រតិបត្តិការនៅ CGCC ដែលជាសហគ្រាសសាធារណៈ ស្ថិតក្រោមក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ក្នុងរយៈពេល ២ឆ្នាំមកនេះ ខ្ញុំបានប្រើប្រាស់ចំណេះដឹង ជំនាញ និងបទពិសោធន៍របស់ខ្ញុំក្នុងការអនុវត្តភារកិច្ចស្នូលរបស់ខ្ញុំប្រកបដោយធនធ: និងការទទួលខុសត្រូវដើម្បីវាយតម្លៃលើសំណើសុំការធានាឥណទានលើកម្ចីរបស់គ្រឹះស្ថានហិរញ្ញវត្ថុចូលរួម (PFIs) មកកាន់ CGCC និងធានាថាការលិខិតធានាឥណទាន ត្រូវបានផ្តល់ជូន PFIs ប្រកបដោយប្រសិទ្ធភាព និងទាន់ពេលវេលា។ ខ្ញុំត្រូវបញ្ជាក់ឱ្យបានថាកម្ចីដែល CGCC ធានា ពិតជាត្រឹមត្រូវតាមលក្ខខណ្ឌនៃគម្រោងធានាឥណទានរបស់ CGCC និងពិតជាកម្ចីចាំបាច់របស់ម្ចាស់អាជីវកម្ម ដើម្បីរក្សានិរន្តរភាព និងពង្រីកអាជីវកម្មរបស់ពួកគេ។ ជានិច្ចកាល ខ្ញុំតែងតែបានផ្តល់ការបណ្តុះបណ្តាល និងចែករំលែកចំណេះដឹង ជូនដល់បុគ្គលិករបស់ PFIs អំពីនីតិវិធីនៃការស្នើសុំការធានាឥណទានពី CGCC និងផ្តល់កិច្ចសហការណ៍ក្នុងការដោះស្រាយនូវបញ្ហាផ្សេងៗរបស់ PFIs ដើម្បីពួកគេអាចស្នើសុំ និងទទួលបានការធានាឥណទានពី CGCC ដោយរលូន ទាន់ពេលវេលា ប្រកបដោយប្រសិទ្ធភាព។

ក្រៅពីការងារស្នូលរបស់ខ្ញុំ ខ្ញុំក៏បំពេញតួនាទីបន្ថែមជាអនុប្រធានគណៈកម្មាធិការសង្គមរបស់ CGCC (Staff Social Committee) ផងដែរ។ ខ្ញុំបានចូលរួមផ្ទេចផ្ទើម និងរៀបចំកម្មវិធីបុគ្គលិក និងការងារសង្គមជាច្រើនរបស់ CGCC ដើម្បីបង្កើនចំណងមិត្តភាព រវាងបុគ្គលិករបស់ CGCC និងលើកកម្ពស់សុខមាលភាពសង្គម។

ជាក់ស្តែង ខ្ញុំបានចូលរួមរៀបចំកម្មវិធីសប្បុរសរបស់ CGCC ក្នុងការផ្តល់ម៉ាស៊ីនផលិតទឹកស្អាតមួយ ជូនដល់សិក្សានុសិស្ស និងប្រជាពលរដ្ឋ នៅលើកោះដាច់ស្រយាលមួយក្នុងខេត្តកោះកុង ដើម្បីឱ្យពួកគេអាចទទួលបានទឹកស្អាតសម្រាប់បរិភោគប្រចាំថ្ងៃ និងកាត់បន្ថយការប្រើប្រាស់ផ្លាស់ស្ទិកលើកោះនោះផងដែរ។

នៅ CGCC ខ្ញុំអាចអភិវឌ្ឍចំណេះដឹង និងជំនាញទាំង Hard skills និង Soft skills។ ខ្ញុំមានឱកាសក្នុងការចូលរួមវគ្គបណ្តុះបណ្តាលនានា ទាំងក្នុងនិងក្រៅប្រទេស។ កាលពីឆ្នាំមុន ខ្ញុំបានរួមដំណើរជាមួយគណៈប្រតិភូរបស់ CGCC ដើម្បីធ្វើទស្សនកិច្ចសិក្សាទៅកាន់សាជីវកម្មធានាឥណទានរបស់ថៃ ដែលត្រូវបានដាក់ឱ្យដំណើរការ តាំងពីឆ្នាំ១៩៩១។ ដំណើរទស្សនកិច្ចនេះ បានជួយខ្ញុំឱ្យយល់កាន់តែស៊ីជម្រៅអំពីអាជីវកម្មធានាឥណទាន។

សម្រាប់ខ្ញុំ ស្ថាប័នដែលល្អសម្រាប់បំពេញការងារគឺជាស្ថាប័នដែលមានចក្ខុវិស័យបេសកកម្ម និងគោលដៅច្បាស់លាស់ ព្រមទាំងមានវប្បធម៌ចែករំលែកការលើកទឹកចិត្ត និងការយកចិត្តទុកដាក់ចំពោះបុគ្គលិក តាមរយៈការផ្តល់ឱកាសអភិវឌ្ឍចំណេះជំនាញ និងសមត្ថភាពបន្ថែមដល់បុគ្គលិក។ ខ្ញុំពិតជាមោទនភាពដែលបានចូលរួមចំណែកបំពេញបេសកកម្មជាមួយ CGCC ក្នុងការបង្កើនបរិយាបន្នហិរញ្ញវត្ថុ និងគាំទ្រការអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យម នៅកម្ពុជា ដើម្បីបង្កើនការងារ និងប្រាក់ចំណូលជូនប្រជាជនរបស់ប្រទេសរបស់ខ្ញុំ។

EN With experience in the banking sector, particularly in credit risk management, I decided to join CGCC, a state-owned enterprise under the Ministry of Economy and Finance, as a Senior Executive of Credit Administration in December 2021.

For the past 2 years, I have utilized my knowledge, skills, and experience to carry out my core tasks responsibly and diligently to evaluate PFIs' guaranteed loan applications to CGCC and to ensure that CGCC's credit guarantees are provided to PFIs in an efficient and timely manner. I have to verify that the loans that CGCC guarantees comply with the terms and conditions of the CGCC credit guarantee schemes and are necessary loans for business owners to sustain and expand their businesses. From time to time, I have provided training and knowledge sharing to PFI staff on CGCC loan application procedures and supported them in resolving issues so that they can apply for and receive credit guarantees from CGCC smoothly, timely, and efficiently.

In addition to my core responsibilities, I am serving as the Vice Chairman of the CGCC Staff Social Committee. I have been involved in initiating and organizing many CGCC staff engaging and social programs to increase friendships and promote social well-being. For instance, I helped organizing a CGCC charity to provide a water purifier to students and residents on a remote island in Koh Kong province to help them access clean drinking water and reduce plastic bottled water on the island.

At CGCC, I can develop knowledge as well as hard and soft skills. I have had the opportunity to attend both domestic and international training programs. Last year, I joined CGCC delegates to conduct a study visit to the Thai Credit Guarantee (TCG) to learn about their credit guarantee system, which has been operationalized since 1991. This study visit has deepened my understanding of the credit guarantee business.

For me, a good company to work for is a company that has a clear vision, mission, and goals, as well as a culture of sharing, motivating, and caring by providing opportunities for employees to develop knowledge, skills, and abilities. I am proud to be a part of the CGCC's mission to improve financial inclusion and support the development of SMEs in Cambodia to increase employment and income for the people of my country.

កីឡា និងមិត្តភាពរវាង CGCC និងដៃគូពាក់ព័ន្ធ | Sport & Friendship Between CGCC and Related Stakeholders

KH CGCC លើកកម្ពស់តុល្យភាពរវាងជីវិត និងការងារ។ CGCC បានបង្កើតក្រុមកីឡាបាល់ទាត់ ដើម្បីប្រកួតមិត្តភាពរវាង CGCC និងដៃគូពាក់ព័ន្ធ ដើម្បីសុខភាព មិត្តភាព និងសាមគ្គីភាព ដោយមានការសម្របសម្រួលពីលោក Smas Aroza ប្រធានការិយាល័យហិរញ្ញវត្ថុ និងវិភាគអាជីវកម្ម និងជាប្រធានគណៈកម្មាធិការសង្គមរបស់ CGCC។ ការប្រកួតបាល់ទាត់មិត្តភាពរវាង CGCC និងដៃគូពាក់ព័ន្ធត្រូវបានរៀបចំឡើងជាប្រចាំជារៀងរាល់សប្តាហ៍។

EN CGCC believes in work-life balance. CGCC established a football team to have friendly matches between CGCC and related stakeholders to promote health, friendship, and solidarity under the facilitation of Mr. Smas Aroza, Manager of Finance and Business Analytics Department and Chairman of CGCC's Staff Social Committee. Friendly football matches between CGCC and related stakeholders are conducted once a week.

"កីឡាបាល់ទាត់គឺដើម្បីសុខភាព និងមិត្តភាព។ ទីលានមិនមែនគ្រាន់តែជាកន្លែងសម្រាប់រកគ្រាប់បាល់នោះទេ វាគឺជាកន្លែងដែលមិត្តភាពត្រូវបានពង្រឹង ហើយរាល់ការទាត់គឺឆ្លុះបញ្ចាំងពីស្មារតីរួមនៃការខិតខំប្រឹងប្រែងរួមគ្នារបស់យើង"។

"Soccer is for health and friendship. The field isn't just a place for goals; it's where friendships are strengthened, and every kick resonates with the shared spirit of our collective pursuit."

លោក ស្មាស់ អារ៉ូហ្សា ប្រធានការិយាល័យហិរញ្ញវត្ថុ និងវិភាគអាជីវកម្ម

Mr. Smas Aroza, Manager of Finance and Business Analytics

វឌ្ឍនភាពការធានាឥណទាន | Credit Guarantee Progress

ដោយ៖ លោកស្រី ពិន ម៉ានីកា ប្រធានការិយាល័យទីផ្សារ និងអភិវឌ្ឍន៍អាជីវកម្ម | By: Ms. Pin Manika, Manager of Marketing and Business Development

គណនីដែលមានការធានា (GA) Guaranteed Account (GA) **1928**	ឥណទានដែលមានការធានា (GL) Guaranteed Loan (GL) **USD 164.72million Equi.**	សន្និធិឥណទានដែលមានការធានា Outstanding Guaranteed Loan **USD 116.13million Equi.**
សន្និធិទំហំការធានាឥណទាន Outstanding Guaranteed Amount **USD 116.13million Equi.**	ភាគរយឥណទានមិនដំណើរការ NPL Ratio of Outstanding Guaranteed Amount **6.68%**	ទំហំសំណងដែលបានបញ្ចេញ Claim Payout **USD 250,215** **KHR 105,574,697**

ក្រុមហ៊ុនហិរញ្ញវត្ថុចូលរួមដែលស្នើសុំការធានាឥណទានបានច្រើនជាងគេ (តុលា-ធ្នូ ២០២៣)
PFIs requesting the most credit guarantees (October-December 2023)

ធនាគារ ការណាឌីយ៉ា 加華銀行 CANADIA BANK | ធនាគារ ស្ថាបនា SATHAPANA BANK | ABA BANK NATIONAL BANK OF CANADA GROUP

គិតត្រឹមត្រីមាសចុងក្រោយនៃឆ្នាំ២០២៣ សាជីវកម្មធានាឥណទានកម្ពុជា (CGCC) បានអនុម័តការធានាសម្រាប់កម្ចីអាជីវកម្មសរុបចំនួន ១៩២៨ ដែលមានទំហំប្រមាណ ១៦៤,៧២ លានដុល្លារ។ គួសបញ្ជាក់ផងដែរថា ក្នុងនោះកម្ចីចំនួន១៩៤ ត្រូវបានទទួលការធានានៅក្នុងឆ្នាំ២០២១ ជាមួយនឹងការកើនឡើងគួរឱ្យកត់សម្គាល់ដល់ ៧៩១កម្ចី ក្នុងឆ្នាំ២០២២ និង ៩៤៣កម្ចី ក្នុងឆ្នាំ២០២៣។ ការធានាទាំងនេះត្រូវបានផ្តល់ក្រោមគម្រោងធានាឥណទានចម្បងចំនួន៥ របស់ CGCC៖ គម្រោងធានាឥណទានដើម្បីស្តារអាជីវកម្ម (BRGS) គម្រោងធានាឥណទានសម្រាប់សហហិរញ្ញប្បទាន (CFGS) គម្រោងធានាឥណទានសម្រាប់សហគ្រិនស្ត្រី (WEGS) គម្រោងធានាឥណទានសម្រាប់សហហិរញ្ញប្បទានសម្រាប់វិស័យទេសចរណ៍ (CFGS-TR) និងគម្រោងធានាឥណទានជាកញ្ចប់ (PGS)។ ក្នុងចំណោមទំហំកម្ចីសរុបដែលមានការធានារបស់ CGCC ត្រឹមចុងត្រីមាសទី៤ ឆ្នាំ២០២៣ សន្និធិទំហំការធានាឥណទានសរុបគឺមានចំនួន ៨៣,៦៥ លានដុល្លារ ដែលនេះគឺជាទំហំហានិភ័យសរុបរបស់ CGCC ដែលមាន ។ ក្នុងនោះ មាន៦,៦៨% គឺជាទំហំការធានាឥណទានមិនដំណើរការ (NPL)។ លើសពីនេះ CGCC ក៏បានបង់សងកម្ចីដែលមានការធានាចំនួន ៧ ដែលបាត់បង់ ក្នុងទំហំជិត $២៧៦.០០០ ក្នុងឆ្នាំ២០២៣។

By the close of the last quarter in 2023, the Credit Guarantee Corporation of Cambodia (CGCC) had approved guarantees for a cumulative total of 1,928 business loans, amassing a substantial loan volume of approximately $164.72 million. Highlighting the trajectory, 194 loans received guarantees in 2021, with a notable uptick to 791 loans in 2022 and 943 loans in 2023. These guarantees were approved under CGCC's five guarantee schemes: the Business Recovery Guarantee Scheme (BRGS), the Co-Financing Guarantee Scheme (CFGS), the Women Entrepreneurs Guarantee Scheme (WEGS), the Co-Financing Guarantee Scheme for Tourism (CFGS-TR), and the Portfolio Guarantee Scheme (PGS). CGCC's total loan portfolio exposure as of December 2023 amounting to $83.65 million, with 6.68% attributed to non-performing loans (NPL). CGCC has also paid claims to 7 loan loss accounts, equivalent to almost $276,000.

១. ការធានាឥណទានប្រចាំខែ |Guarantee Progress by Months

ចាប់ពីពាក់កណ្តាលឆ្នាំ២០២៣មក យើងសង្កេតឃើញមានការធ្លាក់ចុះគួរឱ្យកត់សម្គាល់នូវនិន្នាការធានាឥណទានរបស់ CGCC។ ដោយនៅក្នុងត្រីមាសទីពីរនៃឆ្នាំ២០២៣ CGCC បានផ្តល់ការធានាឥណទានចំនួន ២៩១កម្ចី ស្មើនឹង $១៩,៣៤ លានដុល្លារ ចំណែកឯនៅក្នុងត្រីមាសបន្ទាប់ ការធានាឥណទានសរុបបានថយចុះមកនៅត្រឹម ១៩៦កម្ចី ស្មើនឹង $១៦,២៦លានដុល្លារ ហើយក៏បានធ្លាក់ចុះមកត្រឹម ១៦៦កម្ចីតែប៉ុណ្ណោះនៅក្នុងត្រីមាសចុងក្រោយនៃឆ្នាំ២០២៣ ស្មើនឹង១៥,៥២លានដុល្លារ។

From mid-2023, there has been a slight decrease in CGCC's credit guarantee. In the second quarter of 2023, CGCC guaranteed 291 loans amounting to $19.34 million, whereas in the subsequent quarter, the total credit guarantees diminished to 196 loans, equivalent to $16.26 million, then it went down to down to 166 loans only in the last quarter of 2023, equivalent to $15.52 million.



	2021		2022		Jan		Feb		Mar		Apr		May		Jun		Jul		Aug		Sep		Oct		Nov		Dec	
	GL	GA	GL	GA	GL	GA	GL	GA	GL	GA	GL	GA	GL	GA	GL	GA	GL	GA	GL	GA	GL	GA	GL	GA	GL	GA	GL	GA
PGS	21.3mil	194	71.4mil	791	0	0	.6mil	31	.5mil	29	.2mil	10	.2mil	10	.5mil	28	.3mil	18	.3mil	14	.05mil	3	.38mil	17	.16mil	5	.22mil	8
IGS					5.5mil	60	6.0mil	79	8.3mil	91	6.6mil	82	6.7mil	88	5.2mil	73	6.5mil	64	5.1mil	57	4.0mil	40	5.2mil	46	4.8mil	50	4.7mil	40

*Exchange Rate: USD1 = KHR4,085 *IGS : Individual Guarantee Scheme *PGS : Portfolio Guarantee Scheme

ក្រៅពីនិន្នាការធ្លាក់ចុះនៃចំនួនគណនីមានធានា CGCC ក៏សង្កេតឃើញនិន្នាការកើនឡើងនៃសមាមាត្រ រវាងសន្ទិធិទំហំការធានាឥណទានមិនដំណើរការ (NPL Outstanding Amount) ធៀបនឹងសន្ទិធិទំហំការធានាឥណទានសរុបក្នុងឆ្នាំ២០២៣ ដោយចាប់ផ្តើមពី ១,៤៣% នៅដើមត្រីមាសទី២ និងបន្តកើនឡើងយ៉ាងខ្លាំងដល់ ៦,៦៨% នៅត្រឹមចុងខែធ្នូ។ ក្នុងនោះ យើងសង្កេតឃើញថា កម្ចីដែលខូចខាតភាគច្រើន គឺជាកម្ចីដែលត្រូវបានយកទៅប្រើប្រាស់នៅក្នុងអាជីវកម្មលក់ដុំ និងរាយភេសជ្ជៈ និងគ្រឿងទេស, អាជីវកម្មលក់គ្រឿងសំណង់, អាជីវកម្មជួញដូរផលិតផលកសិកម្ម និងអាជីវកម្មលក់សំលៀកបំពាក់ និងគ្រឿងអេឡិចត្រូនិចជាដើម។

Beside this downturn trend of Guaranteed Accounts, CGCC also observes the increasing trend of NPL ratio of Guaranteed Amount in 2023, starting from 1.43% in the start of second quarter and increasing gradually to 6.68% by the end December. It's evident that the majority of loan losses occur within wholesale and retail sectors, particularly in beverages and groceries sales, construction materials trading, agricultural products trading, as well as clothing and electronics retail.



២. ប្រភេទ និងទំហំកម្ចី |Types and Sizes of Guaranteed Loans

កម្ចីមានកាលកំណត់ គឺជាប្រភេទកម្ចីដែលមានការធានា ច្រើនជាងគេគឺមានចំនួន ១៥២៨កម្ចី ហើយក្នុងចំណោមចំនួនកម្ចីដែលមានការធានាសរុប មានជាង ៧៨% ត្រូវបានយកទៅប្រើប្រាស់ធ្វើជាទុនបង្វិល ដែលស្មើនឹង១៥១០កម្ចី។ ផ្ទុយទៅវិញ មានតែកម្ចីចំនួន៤១៣ប៉ុណ្ណោះ ដែលត្រូវបានផ្តល់ការធានាសម្រាប់យកទៅប្រើប្រាស់ជាទុនវិនិយោគ ឬក្នុងការពង្រីកអាជីវកម្ម។ កម្ចីប្រហាក់ប្រហែល៩២% ត្រូវបានស្នើសុំការធានាពីសហគ្រាសខ្នាតមីក្រូ តូច និងមធ្យម (MSMEs) ដោយ ១៥១កម្ចី ត្រូវបានស្នើសុំដោយសហគ្រាសខ្នាតធំ។ នេះគួសបញ្ជាក់អំពីតម្រូវការក្នុងទីផ្សារដែលកំពុងតែបន្តមាន នោះគឺភាពចាំបាច់របស់ទុនបង្វិលក្នុងដំណើរការអាជីវកម្មប្រចាំថ្ងៃឱ្យកាន់តែរលូន ជាពិសេសសម្រាប់អាជីវកម្ម MSMEs។

ជាង៥៧% នៃប្រាក់កម្ចីដែលមានការធានាសរុប គឺស្ថិតនៅក្នុងចន្លោះ ៥0.000ដុល្លារ ឬតិចជាងនេះ ដែលជាទំហំប្រាក់កម្ចីដែលសមស្រប និងអំណោយផលដល់ការបំពេញតម្រូវការដើមទុនបង្វិលរបស់សហគ្រាសខ្នាតមីក្រូ តូច និងមធ្យម មិនថាសម្រាប់ការប្រើប្រាស់រយៈពេលវែង ឬរយៈពេលខ្លីនោះទេ។ លើសពីនេះ ប្រហែល ៦២,៤% (១២0៣កម្ចី) នៃកម្ចីដែលមានការធានាទាំងអស់ ជាកម្ចីដែលមិនមានទ្រព្យធានា ដែលនេះបង្ហាញពីភាពបត់បែននៃយន្តការធានាឥណទានរបស់CGCC ក្នុងការបង្កើនជម្រើសហិរញ្ញប្បទានជូនទៅកាន់ MSMEs។

Term loans stand out as the prevailing type of guaranteed loans, constituting 1,528 out of the total, with over 78% designated for working capital needs, encompassing 1,510 loans. Conversely, 413 loans are earmarked for investment or business expansion endeavors. Within the spectrum of 1,928 business loans, a striking 92% are sourced from micro, small, and medium enterprises (MSMEs), leaving a modest 151 attributed to large firms. This underscores the persisting and pressing demand for working capital among business proprietors, particularly MSMEs.

Over 57% of total guaranteed loans fall within the bracket of $50,000 or less, an optimal loan size conducive to fulfilling the working capital requirements of micro, small, and medium enterprises, be it for long-term or short-term objectives. Furthermore, approximately 62.4% (1,203 loans) of all guaranteed loans remain unsecured, signifying a strategic flexibility of CGCC's credit guarantee mechanism in diversifying financing options for MSMEs.













៣. ភូមិសាស្ត្ររបស់កម្ចីដែលមានការធានា |Geographical Coverage (IGS)

CGCC នៅតែរក្សាការប្តេជ្ញាចិត្តយ៉ាងខ្ជាប់ខ្ជួនរបស់ខ្លួន ក្នុងការជំរុញកំណើនអភិវឌ្ឍន៍របស់សហគ្រាសខ្នាតមីក្រូ តូច និងមធ្យមទូទាំងប្រទេស ដោយបានពង្រីកវិសាលភាពការធានាឥណទានរបស់ខ្លួនឱ្យគ្របដណ្ដប់បានទូទាំង២៥ រាជធានី-ខេត្ត។ គួរឱ្យកត់សម្គាល់ផងដែរថា CGCCបានបង្កើនជាលំដាប់នៃការផ្ដល់ការធានានៅក្នុងខេត្តនីមួយៗ។ ភ្នំពេញនៅតែជាកន្លែងដែលប្រមូលផ្ដុំការធានាឥណទានខ្ពស់ជាងគេបំផុតនៅក្នុងប្រទេស ដោយយើងសង្កេតឃើញមានការកើនឡើងជាលំដាប់ គឺកើនឡើងពី៥២៣កម្ចី នៅចុងត្រីមាសទី៣ ក្នុងឆ្នាំ២០២៣ មកដល់៥៧៤កម្ចី នៅចុងបញ្ចប់នៃត្រីមាសទី៤។ នេះជានិន្នាការវិជ្ជមានមួយ ដោយបណ្ដាខេត្តផ្សេងទៀតក៏មានការកើនឡើងនៃកម្ចីដែលមានការធានាផងដែរ ដោយក្នុងនោះខេត្តបាត់ដំបង សរុប១៧៥កម្ចី ខេត្តព្រៃវែង៩៣កម្ចី ខេត្តសៀមរាប៩០កម្ចី ខេត្តកំពង់ធំ ៨១កម្ចី និងខេត្តបន្ទាយមានជ័យ៨០កម្ចី។ CGCC នៅតែមានការតាំងចិត្តខ្ពស់ក្នុងការធានានូវនិរន្តរភាពនៃកិច្ចខិតខំប្រឹងប្រែងទាំងនេះ ដែលបង្ហាញឱ្យឃើញតាមរយៈវិធានការសកម្មនានារបស់ខ្លួន ដូចជាការចូលរួមជាមួយស្ថាប័នហិរញ្ញវត្ថុចូលរួមក្នុងការរៀបចំសិក្ខាសាលា និងវគ្គបណ្ដុះបណ្ដាលផ្ទាល់របស់CGCCក្នុងការពង្រឹងសមត្ថភាព និងចំណេះដឹងផ្នែកហិរញ្ញវត្ថុជូនម្ចាស់អាជីវកម្មទូទាំងប្រទេស។

CGCC maintains its steadfast commitment to fostering the growth of MSMEs nationwide, broadening the scope of its credit guarantee initiatives to encompass all 25 provinces and cities. Notably, the corporation has registered a steady uptick in guaranteed loans across each province. Phnom Penh retains its status as the hub with the highest concentration of guaranteed loans, witnessing an escalation from 523 loans at the close of the third quarter in 2023 to 574 loans by the conclusion of the fourth quarter. Encouragingly, other provinces have also experienced growth, with Battambang recording 175 loans, Prey Veng 93 loans, Siem Reap 90 loans, Kampong Thom 81 loans, and Banteay Mean Chey 80 loans. CGCC remains resolute in ensuring the sustainability of these efforts, evident through its proactive measures, including the conduct of roadshows to engage with financial institutions and business owners across various provinces spanning Cambodia's diverse regions and CGCC's own training programs to build MSMEs business skill and financial knowledge.



៤. សមាសភាពអ្នកខ្ចី | Gender

នៅក្នុងការខិតខំប្រឹងប្រែងបន្តរបស់ខ្លួនក្នុងការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ និងការពង្រឹងសេដ្ឋកិច្ច CGCC បានផ្ដល់អាទិភាពក្នុងការផ្ដល់ការធានាឥណទានដល់សហគ្រិនស្ត្រី ដោយទទួលស្គាល់ពីតួនាទីសំខាន់របស់ពួកគេក្នុងការជំរុញការអភិវឌ្ឍប្រកបដោយចីរភាព តាមរយៈការបង្កើតជាផលិតផលធានាឥណទានថ្មីៗ ដែលមានភាពអនុគ្រោះខ្ពស់សម្រាប់សហគ្រិនស្ត្រី។ គំនិតផ្តួចផ្តើមជាយុទ្ធសាស្ត្រនេះ បានផ្ដល់លទ្ធផលជាក់ស្ដែង ដោយសមាមាត្រនៃម្ចាស់អាជីវកម្មជាស្ត្រីមានការកើនឡើងជាលំដាប់ចាប់តាំងពីការចាប់ផ្ដើមរបស់ CGCC។ គិតត្រឹមត្រីមាសទី៣ នៃឆ្នាំ២០២៣ សហគ្រិនស្ត្រីមានចំនួនជាង៤២% ស្មើនឹង៨១១កម្ចី ពោលគឺកើនឡើងយ៉ាងខ្លាំង២៣% ក្នុងឆ្នាំ២០២១ និង៣៥% ត្រឹមចុងឆ្នាំ២០២២។ លទ្ធផលនេះបានគូសបញ្ជាក់ពីការយកចិត្តទុកដាក់របស់ CGCC ក្នុងការជំរុញសមភាពយេនឌ័រ និងសមាហរណកម្មរបស់សហគ្រិនស្ត្រីទៅក្នុងប្រព័ន្ធហិរញ្ញវត្ថុ និងហិរញ្ញប្បទានផ្លូវការ។

In its ongoing pursuit of fostering inclusivity and economic empowerment, CGCC has prioritized the provision of credit guarantees to women entrepreneurs, recognizing their pivotal role in driving sustainable development. CGCC has been designing and implementing various guarantee schemes with favorable conditions for women entrepreneurs. This strategic initiative has yielded tangible results, with the proportion of female business owners experiencing a steady ascent since its inception. As of the third quarter of 2023, female entrepreneurs accounted for nearly 42% (811 loans) of the total borrower base, marking a substantial increase from 23% in 2021 and 35% by the close of 2022. This trajectory underscores CGCC's dedication to fostering gender parity and facilitating the integration of women entrepreneurs into formal financial ecosystems.



វឌ្ឍនភាពនៃប្រព័ន្ធផ្សព្វផ្សាយរបស់ CGCC | CGCC's Digital Marketing Progress



KH នៅក្នុងត្រីមាសទី៤ នៃឆ្នាំ២០២៣ នេះ បណ្តាញប្រព័ន្ធផ្សព្វផ្សាយសង្គមរបស់ CGCC កាន់តែសកម្ម និងទទួលស្គាល់ដោយ សាធារណជនកាន់តែច្រើន។ គេហទំព័ររបស់ CGCC ក៏ទទួលបានការចូលមើលគួរឱ្យកត់សម្គាល់ ដោយសារយើងខ្ញុំបានបង្កើតឡើងមាតិកាសំខាន់ៗ ជាក់លាក់ និងថ្មីៗជានិច្ចទាក់ទងនឹងវឌ្ឍនភាពនៃការធានាឥណទាន សកម្មភាពនិងព្រឹត្តិការណ៍ និងព័ត៌មានប្រកបដោយចំនេះដឹងទាក់ទងនឹងការធានាឥណទាន។

EN In this 4th quarter of 2023, CGCC's social media channels have been more active and recognized by more audiences. CGCC's website also receives noticeable visits generated by our genuinely and constantly updated contents regarding the credit guarantee progress, activities and events, and other resourceful information related to credit guarantee.

ប្រព័ន្ធផ្សព្វផ្សាយសង្គម និងគេហទំព័ររបស់ CGCC ដំណើរការក្នុងត្រីមាសទី៤ ឆ្នាំ២០២៣ រួមមាន៖

CGCC's social media and website progress in the 4th Quarter of 2023:

636 New Likes

187 New Likes

178 New Followers

5.8K New Visitors

កិច្ចសហប្រតិបត្តិការ និងសកម្មភាពនានា | Cooperation and activities

កិច្ចសហប្រតិបត្តិការ និងភាពជាដៃគូ | Cooperation and partnership

សាជីវកម្មធានាឥណទានកម្ពុជា (CGCC) បានចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នា (MoU) ជាមួយសាជីវកម្មធានាឥណទានថៃ

Credit Guarantee Corporation Cambodia (CGCC) Signed a Memorandum of Understanding (MoU) with Thai Credit Guarantee Corporation (TCG)

នៅថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២៣ នៅទីក្រុងបាងកក ព្រះរាជាណាចក្រថៃ ដោយទទួលបានការឯកភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សាជីវកម្មធានាឥណទានកម្ពុជា (CGCC) បានចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នា (MoU) ជាមួយសាជីវកម្មធានាឥណទានថៃ (TCG) ក្រោមវត្តមានដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តមបណ្ឌិត ម៉ី វ៉ាន់ រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការគ្រប់គ្រងហានិភ័យរបស់ CGCC ដើម្បីបង្កើតកិច្ចសហប្រតិបត្តិការរវាង CGCC និង TCG លើការអភិវឌ្ឍយន្តការធានាឥណទានតាមរយៈការផ្លាស់ប្តូរព័ត៌មាន ចំណេះដឹង ជំនួយបច្ចេកទេស និងការប្រឹក្សាយោបល់គ្នាទៅវិញទៅមក។

Read more in English: https://www.cgcc.com.kh/en/article/13815/

ជំនួបសម្តែងការគួរសមរបស់ CGCC ជាមួយធនាគារកសិកន នៅប្រទេសថៃ

Courtesy Visit by CGCC to Kasikornbank in Thailand

នៅថ្ងៃសុក្រ ទី០១ ខែធ្នូ ឆ្នាំ២០២៣ នៅទីក្រុងបាងកក ប្រទេសថៃ ឯកឧត្តមបណ្ឌិត ម៉ី វ៉ាន់ រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការគ្រប់គ្រងហានិភ័យ របស់សាជីវកម្មធានាឥណទានកម្ពុជា (CGCC) បានដឹកនាំគណៈប្រតិភូ CGCC ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារជាមួយលោក Suwat Techawatanawana អគ្គនាយកប្រតិបត្តិរង ធនាគារកសិកនប្រទេសថៃ នៅការិយាល័យរបស់ធនាគារកសិកនប្រទេសថៃ ដោយមានការចូលរួមពីថ្នាក់គ្រប់គ្រងរបស់ធនាគារកសិកនប្រទេសថៃ និងសាខាធនាគារកសិកន (ភ្នំពេញ) ដែលជាគ្រឹះស្ថានហិរញ្ញវត្ថុចូលរួមមួយរបស់ CGCC។

Read more in English: https://www.cgcc.com.kh/en/article/13594/

កិច្ចប្រជុំរវាង CGCC, ADB និង GGGI ដើម្បីពិភាក្សាលើលទ្ធភាពសហប្រតិបត្តិការដើម្បីហិរញ្ញប្បទានបៃតងប្រកបដោយចីរភាព

Meeting Between CGCC, ADB, and GGGI to explore the collaboration on Cambodian Green Sustainable Financing

នាថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០២៣ នៅការិយាល័យ CGCC លោក Wong Keet Loong អគ្គនាយក CGCC បានដឹកនាំក្រុមការងារ CGCC ជួបជាមួយតំណាងធនាគារអភិវឌ្ឍន៍អាស៊ី (ADB) និង Global Green Growth Institute (GGGI) ដើម្បីពិភាក្សាលើគម្រោង Switch Garment របស់ GGGI ក្នុងគោលបំណងគាំទ្រដល់ការអនុវត្តថាមពលប្រកបដោយចីរភាព នៅក្នុងវិស័យកាត់ដេរកម្ពុជា។

តាមរយៈកិច្ចប្រជុំនេះផងដែរ ស្ថាប័នទាំងបី បានចូលរួមចែករំលែក និងផ្លាស់ប្តូរទស្សនៈយោបល់នានា ដើម្បីស្វែងរកលទ្ធភាពកិច្ចសហប្រតិបត្តិការ ក្នុងការអនុវត្តគម្រោងហិរញ្ញប្បទានបៃតងប្រកបដោយចីរភាព ដែលរួមមានហិរញ្ញប្បទានក្នុងលក្ខខណ្ឌអនុគ្រោះ ការធានាឥណទាន និងជំនួយបច្ចេកទេសដើម្បីគាំទ្រដល់គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDG)។

Read more in English: https://www.cgcc.com.kh/en/article/13628/

កិច្ចពិភាក្សាស្វែងយល់ និងពង្រឹងកិច្ចសហការលើការធានាឥណទានរវាង CGCC និងគ្រឹះស្ថានហិរញ្ញវត្ថុចូលរួម សាខាខេត្តក្រចេះ ស្ទឹងត្រែង រតនគីរី និងមណ្ឌលគីរី

CGCC's visit to PFIs provincial branches in Kratie, Steung Treng, Ratanakiri & Mondulkiri to Enhance Collaboration on the Credit Guarantee

កាលពីថ្ងៃទី១១ ដល់ថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២៣ សាជីវកម្មធានាឥណទានកម្ពុជា (CGCC) ដឹកនាំដោយ លោកស្រី ពិន ម៉ានីកា ប្រធានការិយាល័យទីផ្សារ និងអភិវឌ្ឍន៍អាជីវកម្ម បានជួបពិភាក្សាស្វែងយល់អំពីការអនុវត្តគម្រោងធានាឥណទាន និងផ្សព្វផ្សាយបន្ថែមអំពីគម្រោងធានាឥណទានរបស់ CGCC ដោយផ្ទាល់ជាមួយថ្នាក់ដឹកនាំ និងបុគ្គលិករបស់សាខានៃគ្រឹះស្ថានហិរញ្ញវត្ថុចូលរួម (PFIs) មួយចំនួនរបស់ CGCC រួមមាន៖

- នៅខេត្តក្រចេះ រួមមាន ធនាគារ ABA
- នៅខេត្តស្ទឹងត្រែង រួមមាន ធនាគារព្រីនស៍ និងធនាគារហ្វីលីព
- នៅខេត្តរតនគីរី រួមមាន ធនាគារកាណាឌីយ៉ា និងធនាគារព្រីនស៍
- នៅខេត្តមណ្ឌលគីរី រួមមាន ធនាគារកាណាឌីយ៉ា និងធនាគារ ABA

កិច្ចពិភាក្សាជាមួយ PFIs របស់ CGCC នៅខេត្តទាំងបួន ដែលជាខេត្តមានសក្តានុពលនៃអាជីវកម្មរបស់សហគ្រាសខ្នាតតូច និងមធ្យម គឺជាឱកាសមួយដ៏ពិសេសសម្រាប់ទាំង CGCC និង PFIs ស្វែងយល់អំពីភាពចាំបាច់នៃការធានាឥណទាន និងឱកាសដែល PFIs អាចបង្កើនការផ្តល់កម្ចីជូនទៅដល់ក្រុមហ៊ុនអាជីវកម្ម ដែលមានតម្រូវការកម្ចីតែខ្ទះទ្រព្យធានា។

Read more in English: https://www.cgcc.com.kh/en/article/13838/

ការផ្សព្វផ្សាយបង្កើនការយល់ដឹងអំពីការធានាឥណទាន | Raising Awareness of Credit Guarantee

CGCC ចូលរួមក្នុង “ទិវាសហគ្រិនស្ត្រីកម្ពុជា” ចែករំលែកពីយន្តការគាំទ្ររបស់រាជរដ្ឋាភិបាលដល់សហគ្រិនស្ត្រី តាមរយៈការធានាឥណទាន

CGCC Participating in the Women Entrepreneurs Day to share about Government’s Mechanism to support women entrepreneurs

នាថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០២៣ លោក ណូ លីដា អគ្គនាយករង CGCC បានដឹកនាំក្រុមការងាររបស់ CGCC ចូលរួមក្នុង “ទិវាសហគ្រិនស្ត្រីកម្ពុជា” ដែលត្រូវបានរៀបចំដោយសមាគមន៍សហគ្រិនស្ត្រីកម្ពុជា ក្រោមប្រធានបទស្តីពី “បញ្ហាប្រឈមរបស់សហគ្រិនស្ត្រីលើកាតព្វកិច្ចបង់ពន្ធ និងទស្សនៈវិស័យនាពេលអនាគត” ដែលមានអ្នកចូលរួមជាង១៥០នាក់ មកពីស្ថាប័នពាក់ព័ន្ធ។

នៅក្នុងវេទិកានេះ លោកស្រី សាន សុខរីណា ប្រធានការិយាល័យអភិវឌ្ឍន៍ផលិតផលនិងសហប្រតិបត្តិការរបស់ CGCC បានចូលរួមជាវាគ្មិនកិត្តិយសនៅក្នុងកិច្ចពិភាក្សាស្តីពី “ការគាំទ្ររបស់រាជរដ្ឋាភិបាលដល់សហគ្រិនស្ត្រី ដែលកំពុងប្រឈមនឹងវិបត្តិសេដ្ឋកិច្ចសកល” ដោយបានចែករំលែកពីគម្រោងធានាឥណទានរបស់ CGCC ជាពិសេស គម្រោងធានាឥណទានសម្រាប់សហគ្រិនស្ត្រីក្នុងការគាំទ្រដល់សហគ្រិនស្ត្រី ឱ្យទទួលបានហិរញ្ញប្បទានចាំបាច់ដើម្បីទ្រទ្រង់និងពង្រីកអាជីវកម្ម។

Read more in English: https://www.cgcc.com.kh/en/article/13400/

សិក្ខាសាលាផ្សព្វផ្សាយ ស្តីពី “កម្ចីដែលមានការធានា ដើម្បីគាំទ្រដល់ការអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យម” នៅខេត្តក្រចេះ

Dissemination Seminar on “Guaranteed Loans to Support the Development of Small and Medium Enterprises” in Kratie Province

ថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០២៣ សាជីវកម្មធានាឥណទានកម្ពុជា (CGCC) និងសភាពាណិជ្ជកម្មកម្ពុជា (CCC) បានសហការរៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពី “កម្ចីដែលមានការធានា ដើម្បីគាំទ្រដល់ការអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យម” នៅឯខេត្តក្រចេះ ក្រោមកិច្ចសហការចូលរួមដោយ សភាពាណិជ្ជកម្មមណ្ឌលខេត្តក្រចេះ ស្ទឹងត្រែង រតនគីរី ដែលក្នុងនោះមានសមាសភាពចូលរួមពីសំណាក់ថ្នាក់ដឹកនាំ និងបុគ្គលិកនៃគ្រឹះស្ថានហិរញ្ញវត្ថុចូលរួម (PFIs) មួយចំនួន និងបណ្តាសហគ្រិនដែលជាម្ចាស់អាជីវកម្មខ្នាតតូច និងមធ្យម នៅក្នុងខេត្តក្រចេះ និងបណ្តាខេត្តផ្សេងៗទៀត ជាង៦០នាក់។ សិក្ខាសាលាផ្សព្វផ្សាយនេះ ទទួលបានការអញ្ជើញចូលរួមជាអធិបតីដោយ លោក កែវ សុទ្ធារិទ្ធ ប្រធានសភាពាណិជ្ជកម្មមណ្ឌល ខេត្តក្រចេះ ស្ទឹងត្រែង រតនគីរី លោក ណូ លីដា អគ្គនាយករង CGCC លោក ហ៊ីយ សិក្សា នាយកប្រតិបត្តិរងនៃសម្ព័ន្ធសហគមន៍កសិកម្មកម្ពុជា ព្រមទាំងការធ្វើបទបង្ហាញរបស់អ្នកតំណាងមកពីធនាគារព្រីនស៍ និងធនាគារហ្ស៊ីលីព ផងដែរ។

តាមរយៈសិក្ខាសាលាផ្សព្វផ្សាយនេះ សហគ្រិននៃអាជីវកម្មខ្នាតតូច និងមធ្យមបានជ្រាបអំពីព័ត៌មាននៃអត្ថប្រយោជន៍ពីកម្ចីដែលមានការធានា តាមរយៈគ្រឹះស្ថានហិរញ្ញវត្ថុចូលរួមរបស់ CGCC ឆ្លើយតបទៅនឹងបញ្ហាខ្វះទ្រព្យធានាពេលស្នើសុំកម្ចី សម្រាប់ពង្រីក និងស្តារអាជីវកម្មរបស់ខ្លួនទៀតផង។

Read more in English: https://www.cgcc.com.kh/en/article/13852/

វេទិកាផ្តួរផ្គងអាជីវកម្មសហគមន៍ ស្តីពី “ការពង្រឹងនិងពង្រីកទីផ្សារផលិតផលកសិកម្ម តាមរយៈការអនុវត្តផលិតកម្មកសិកម្មតាមកិច្ចសន្យា”

A cooperative business linkage event on “Strengthening and Extending the Agricultural Products through Contract Farming Implementation”

កាលពីថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២៣ លោកស្រី ពិន ម៉ានីកា ប្រធានការិយាល័យទីផ្សារ និងអភិវឌ្ឍន៍អាជីវកម្ម តំណាងឱ្យសាជីវកម្មធានាឥណទានកម្ពុជា (CGCC) បានអញ្ជើញចូលរួម វេទិកាផ្តួរផ្គងអាជីវកម្មសហគមន៍ ស្តីពី “ការពង្រឹងនិងពង្រីកទីផ្សារផលិតផលកសិកម្ម តាមរយៈការអនុវត្តផលិតកម្មកសិកម្មតាមកិច្ចសន្យា” ដែលរៀបចំដោយសម្ព័ន្ធសហគមន៍សិកម្មកម្ពុជា (CACA) និងបានធ្វើបទបង្ហាញអំពីគម្រោងធានាឥណទានរបស់ CGCC ក៏ដូចជាអត្ថប្រយោជន៍ពីកម្ចីដែលមានការធានាតាមរយៈគ្រឹះស្ថានហិរញ្ញវត្ថុចូលរួមរបស់ CGCC ដើម្បីឆ្លើយតបទៅនឹងបញ្ហាខ្វះទ្រព្យធានាពេលស្នើសុំកម្ចី សម្រាប់ពង្រីក និងស្តារអាជីវកម្មរបស់ម្ចាស់អាជីវកម្មទូទៅ ជាពិសេសចំពោះម្ចាស់អាជីវកម្មដែលកំពុងតែស្ថិតនៅក្នុងវិស័យកសិកម្មនេះតែម្តង។ វេទិកានេះ មានសមាសភាពចូលរួមពីសំណាក់ ថ្នាក់ដឹកនាំសហគមន៍កសិកម្ម សហភាពសហគមន៍កសិកម្ម និងតំណាងពីស្ថាប័នរដ្ឋ ដៃគូអភិវឌ្ឍ ព្រមទាំងស្ថាប័នឯកជន ប្រមាណសរុបចំនួន ២៣០ នាក់។

Read more in English: https://www.cgcc.com.kh/en/article/13906/

កិច្ចប្រជុំសំខាន់ៗ | Notable Meetings

កិច្ចប្រជុំបុគ្គលិក CGCC លើកទី៣ ប្រចាំឆ្នាំ២០២៣ “ស្តីអំពីវឌ្ឍនភាពប្រចាំត្រីមាសទី៣ និងផែនការការងារសម្រាប់ត្រីមាសទី៤”

CGCC 3rd Town Hall Meeting 2023 to review “Progress in Q3 and Plan in Q4”

នាថ្ងៃទី១០ ខែតុលា ឆ្នាំ២០២៣ សាជីវកម្មធានាឥណទានកម្ពុជា (CGCC) បានរៀបចំកិច្ចប្រជុំបុគ្គលិក CGCC លើកទី៣ ប្រចាំឆ្នាំ២០២៣ ដើម្បីពិនិត្យលើវឌ្ឍនភាពការងារក្នុងត្រីមាសទី៣ និងផែនការការងារក្នុងត្រីមាសទី៤ ឆ្នាំ២០២៣។

កិច្ចប្រជុំបុគ្គលិក CGCC លើកទី៣ ប្រចាំឆ្នាំ២០២៣ មានការចូលរួមពីថ្នាក់ដឹកនាំ និងបុគ្គលិកទាំងអស់របស់ CGCC និងការចូលរួមជាភ្ញៀវកិត្តិយសរបស់ លោក អឿ សុធាវ័ត្ន ប្រធាននាយកប្រតិបត្តិ នៃក្រុមហ៊ុនក្រេឌីត ប្យូរ៉ូ (ខេមបូឌា) (CBC)។ កិច្ចប្រជុំបុគ្គលិក CGCC មិនមែនត្រឹមតែជាវេទិកាដើម្បីពិនិត្យនិងវាយតម្លៃអំពីវឌ្ឍនភាពការងាររបស់ CGCC ប៉ុណ្ណោះទេ ប៉ុន្តែជាឱកាសក្នុងការជួបពិភាក្សា និងផ្លាស់ប្តូរមតិយោបល់យ៉ាងទូលំទូលាយ អំពីស្ថានភាពនៃវិស័យហិរញ្ញវត្ថុ និងធនាគារនៅកម្ពុជាផងដែរ។

Read more in English: https://www.cgcc.com.kh/kh/article/13002/

កិច្ចប្រជុំក្រុមប្រឹក្សាភិបាល CGCC អាណត្តិទី១ លើកទី១៦

16th CGCC Board Meeting of the 1st Mandate of Credit Guarantee Corporation of Cambodia (CGCC)

នៅថ្ងៃទី២៤ ខែតុលា ឆ្នាំ២០២៣ វេលាម៉ោង ២:00នាទីរសៀល CGCC បានរៀបចំកិច្ចប្រជុំក្រុមប្រឹក្សាភិបាលអាណត្តិទី១ លើកទី១៦ តាមរយៈប្រព័ន្ធអនឡាញ ក្រោមវត្តមានដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម រស់ សីលវ៉ា រដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សារបស់ CGCC ដោយមានការចូលរួមពីសមាជិកក្រុមប្រឹក្សាភិបាល និងមន្ត្រីត្រួតពិនិត្យរដ្ឋ។

របៀបវារៈនៃកិច្ចប្រជុំក្រុមប្រឹក្សាភិបាលលើកទី១៦ នេះរួមមាន៖

(១) របាយការណ៍ស្តីពីវឌ្ឍនភាពការងាររបស់ CGCC
(២) ការធានាជាកញ្ចប់ជាមួយធនាគារ ស្ថាបនា គីអ៊ិលស៊ី និង ធនាគារ ព្រីនស៍ ម.ក
(៣) ពាក្យស្នើសុំធ្វើជាគ្រឹះស្ថានហិរញ្ញវត្ថុចូលរួមរបស់ ធនាគារ ប្រ៊ីដ ម.ក
(៤) ក្របខណ្ឌវាយតម្លៃហានិភ័យ និងការត្រួតពិនិត្យ
(៥) គោលនយោបាយវិនិយោគ
(៦) ផែនការរៀបចំមជ្ឈមណ្ឌលសង្គ្រោះទិន្នន័យ
(៧) ការរៀបចំ Module ដើម្បីគ្រប់គ្រងការធានាឥណទានជាកញ្ចប់
(៨) Core Value របស់ ស.ធ.ក.
(៩) ផ្សេងៗ (របាយការណ៍សវនកម្មផ្ទៃក្នុងលើយុទ្ធសាស្ត្រ និងអភិវឌ្ឍន៍អាជីវកម្ម)

កិច្ចប្រជុំក្រុមប្រឹក្សាភិបាល CGCC អាណត្តិទី២ លើកទី១

1st CGCC Board Meeting of the 2nd Mandate of Credit Guarantee Corporation of Cambodia (CGCC)

នៅថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០២៣ វេលាម៉ោង ២:00នាទីរសៀល CGCC បានរៀបចំកិច្ចប្រជុំក្រុមប្រឹក្សាភិបាលអាណត្តិទី២ លើកទី១ នៅឯការិយាល័យកណ្តាលរបស់ CGCC ក្រោមវត្តមានដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម រស់ សីលវ៉ា រដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សារបស់ CGCC ដោយមានការចូលរួមពីសមាជិកក្រុមប្រឹក្សាភិបាល និងមន្ត្រីត្រួតពិនិត្យរដ្ឋ។

របាយការណ៍ស្តីពីវឌ្ឍនភាពការងាររបស់ CGCC

(១) របាយការណ៍ស្តីពីវឌ្ឍនភាពការងាររបស់ ស.ធ.ក.
(២) ពាក្យស្នើសុំធ្វើជាគ្រឹះស្ថានហិរញ្ញវត្ថុចូលរួម
(៣) គម្រោងធានាឥណទានសម្រាប់ការនាំចេញអង្ករ
(៤) គម្រោង Sustainable Green Financing Facility
(៥) គោលនយោបាយវិនិយោគ
(៦) ការបញ្ចប់កិច្ចព្រមព្រៀងធានាឥណទានជាមួយ PFIs
(៧) គុណតម្លៃរបស់ ស.ធ.ក.
(៨) ផ្សេងៗ

ក្រុមប្រឹក្សាភិបាលរបស់ CGCC មានអណត្តិ ៣ឆ្នាំ។ ក្រុមប្រឹក្សាភិបាលអណត្តិទី១ ត្រូវបានតែងតាំងដោយអនុក្រឹត្យ កាលពីថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២២។ ក្រុមប្រឹក្សាភិបាលអណត្តិទី២ ត្រូវបានតែងតាំងដោយអនុក្រឹត្យលេខ១២០៤ អនក្រ.តត សម្រាប់រយៈពេល ៣ឆ្នាំ កាលពីថ្ងៃទី២៤ ខែតុលា ឆ្នាំ២០២៣។

សកម្មភាពផ្សេងៗ | Other Activities

កម្មវិធីវិបស្សនាប្រចាំឆ្នាំ២០២៣ របស់បុគ្គលិក CGCC នៅខេត្តសៀមរាប

CGCC Annual Staff Retreat 2023 in Siem Reap

ដើម្បីរឹតចំណងសាមគ្គីភាព បង្កើនផលិតភាពការងារ និងផ្តែងអំណរគុណដល់បុគ្គលិកទាំងអស់ ក្នុងកិច្ចខិតខំប្រឹងប្រែងចូលរួមចំណែកគាំទ្រដល់ប្រតិបត្តិការនៃការធានាឥណទាន CGCC បានរៀបចំកម្មវិធីវិបស្សនា អមជាមួយវគ្គបណ្តុះបណ្តាលស្តីពី **"Action Leadership for Growth"** ព្រមទាំងសកម្មភាពរឹតចំណងសាមគ្គីក្រុមការងារ (Team Building) ប្រចាំឆ្នាំ២០២៣ នៅខេត្តសៀមរាប ពីថ្ងៃទី៩ ដល់១២ ខែវិច្ឆិកា ឆ្នាំ២០២៣។

តាមរយៈកម្មវិធីនេះ ថ្នាក់ដឹកនាំ និងបុគ្គលិករបស់ CGCC មានឱកាសបានស្វែងយល់ពីគ្នាទៅវិញទៅមក និងបានផ្លាស់ប្តូរបទពិសោធន៍ការងារ ក៏ដូចជាបានជួយបង្កើននូវសមត្ថភាព និងចំណេះដឹងបន្ថែមអំពីគោលគំនិតនិងការអនុវត្តភាពជាអ្នកដឹកនាំសម្រាប់ការអភិវឌ្ឍ ដើម្បីបង្កើនប្រសិទ្ធភាពការងាររបស់ក្រុមការងារ ក៏ដូចជារួមចំណែកដល់ប្រតិបត្តិការ និងការអភិវឌ្ឍរបស់ CGCC ស្របតាមចក្ខុវិស័យក្នុងការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ និងអភិវឌ្ឍសហគ្រាសខ្នាតតូច និងមធ្យមនៅកម្ពុជាផងដែរ។៖

Read more in English: https://www.cgcc.com.kh/en/article/13408/

CGCC ចូលរួមកម្មវិធីបណ្តុះបណ្តាលប្រចាំឆ្នាំ ក្រោមប្រធានបទស្តីពី "SME Finance and Support Measure of Korea" ដែលរៀបចំឡើងដោយ KODIT នៅទីក្រុងសេអ៊ូល សាធារណរដ្ឋកូរ៉េ

CGCC Participating in the Annual Training Program Under the Theme "SME Finance and Support Measure of Korea" Organized by KODIT in Seoul, Republic of Korea

កាលពីថ្ងៃទី២៦ ខែវិច្ឆិកា ដល់ថ្ងៃទី ០១ ខែធ្នូ ឆ្នាំ២០២៣ ក្រោមកិច្ចសហប្រតិបត្តិការរវាងសាជីវកម្មធានាឥណទានកូរ៉េ (KODIT) និងសាជីវកម្មធានាឥណទានកម្ពុជា (CGCC) លោក ញ៉ឹម សូរិយា ប្រធាននាយកដ្ឋានហិរញ្ញវត្ថុនិងវិភាគអាជីវកម្ម និងលោកស្រី ពិន ម៉ានីកា ប្រធានការិយាល័យទីផ្សារ និងអភិវឌ្ឍន៍អាជីវកម្ម របស់ CGCC រួមជាមួយតំណាង ១រូប ពីអគ្គនាយកដ្ឋានគោលនយោបាយ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងតំណាង ១រូបពីអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ បានចូលរួមកម្មវិធីបណ្តុះបណ្តាលប្រចាំឆ្នាំ ក្រោមប្រធានបទស្តីពី "SME Finance and Support Measure of Korea" ដែលរៀបចំឡើងដោយ KODIT នៅទីក្រុងសេអ៊ូល សាធារណរដ្ឋកូរ៉េ ។

កម្មវិធីបណ្តុះបណ្តាលនេះ បានផ្តោតទៅលើការស្វែងយល់អំពីក្របខណ្ឌស្ថាប័នច្បាប់ បទប្បញ្ញត្តិ គម្រោង នីតិវិធីការគ្រប់គ្រងហានិភ័យ និងយន្តការពាក់ព័ន្ធនឹងការធានាឥណទាន ជាពិសេសគម្រោង និងសកម្មភាពនានារបស់ KODIT ដើម្បីគាំទ្រដល់សហគ្រាសខ្នាតតូច និងមធ្យម បរិស្ថាន សង្គម និងអភិបាលកិច្ច (ESG) នៅក្នុងសាធារណរដ្ឋកូរ៉េ។ កម្មវិធីបណ្តុះបណ្តាលនេះបានផ្តល់ឱកាសដល់ក្រុមការងារ CGCC និងអ្នកចូលរួមផ្សេងទៀត ក្នុងការសិក្សាស្វែងយល់ពីបទពិសោធន៍ ឧត្តមានុវត្តល្អ និងយន្តការ នៃការធានាឥណទានថ្មីៗ ដើម្បីបង្កើនប្រសិទ្ធភាពនៃការធានាឥណទានរបស់ CGCC។៖

Read more in English: https://www.cgcc.com.kh/en/article/13863/

ការស្វែងយល់អំពីការធានាឥណទាន | Understanding the Credit Guarantee

ជួបជាមួយគ្រឹះស្ថានហិរញ្ញវត្ថុចូលរួម (ធនាគារ ហ្វីលីព) | Meeting with CGCC's Participating Financial Institution (Phillip Bank)

លោក ចាន់ ម៉ាច អភិបាល និងអគ្គនាយក
MR. CHAN MACH,
Director and Chief Executive Officer

១. តើធនាគារ ហ្វីលីព យល់ឃើញដូចម្តេច ចំពោះគម្រោងធានាឥណទាន? ហេតុអ្វីបានជា ហ្វីលីព ចូលរួមជាដៃគូជាមួយ CGCC?

What is Phillip Bank's perspective towards the credit guarantee schemes and why does PhillipBank partner with CGCC?

CGCC មានគម្រោងធានាឥណទានជាច្រើន ដែលអាចជួយដល់ម្ចាស់អាជីវកម្មដែលគ្មានទ្រព្យធានា ដើម្បីទទួលបានប្រាក់កម្ចីផ្លូវការ សម្រាប់អាជីវកម្មរបស់ពួកគាត់។ គម្រោងនេះបានផ្តល់ភាពងាយស្រួល ដល់ម្ចាស់អាជីវកម្មដែលមានសក្តានុពល ប៉ុន្តែគ្មាន ឬខ្វះទ្រព្យធានា និងសហគ្រិនស្ត្រី។ គម្រោងធានាឥណទានរបស់ CGCC ក៏ជួយកាត់បន្ថយហានិភ័យឥណទានរបស់ធនាគារចំនួន 70%-80% ផងដែរ។

មូលហេតុដែលធនាគារ ហ្វីលីពសហការជាមួយ CGCC៖

- ចូលរួមជាមួយរាជរដ្ឋាភិបាលដើម្បីគាំទ្រ MSMEs
- ជួយម្ចាស់អាជីវកម្មដែលខ្វះខាតទ្រព្យធានា ដើម្បីទទួលបានកម្ចីក្នុងការដំណើរការ និងពង្រីកអាជីវកម្មរបស់ពួកគាត់។
- ជួយលើកស្ទួយដល់សហគ្រិនស្ត្រី
- ជំរុញកំណើនសេដ្ឋកិច្ចនៅកម្ពុជា និងកាត់បន្ថយភាពក្រីក្រ

CGCC launched many credit guarantee schemes that can help businesses that do not have collateral to get formal loans for their businesses. These guarantee schemes support potential businesses that do not have collateral and women-owned businesses. The schemes share 70%-80% of the risk with the banks.

Reasons for Phillip Bank to join the CGCC:

- Join with government to help MSMEs
- Help borrowers who lack collaterals to operate and expand their businesses
- Empower women entrepreneurs
- Boost the economic growth in Cambodia and reduce poverty

២. តើគម្រោងធានាឥណទានបានផ្តល់អត្ថប្រយោជន៍ដូចម្តេចខ្លះចំពោះ ធនាគារ ហ្វីលីព និងអតិថិជន?

How do the credit guarantee schemes benefit Phillip Bank and your customers?

CGCC បានជួយធនាគារ ឱ្យបង្កើនការបញ្ចេញកម្ចី ដោយបានផ្តល់ការធានាលើកម្ចីរបស់ម្ចាស់អាជីវកម្មដែលមានសក្តានុពល ប៉ុន្តែគ្មានទ្រព្យធានា និងកាត់បន្ថយអត្រាហានិភ័យឥណទានពី 70%-80%។ សម្រាប់ម្ចាស់អាជីវកម្ម ពួកគាត់អាចទទួលបានកម្ចីតាមតម្រូវការ ដោយមានអត្រាទាប និងការប្រឹក្សាយោបល់ល្អៗអំពីការប្រើប្រាស់កម្ចីដោយការទទួលខុសត្រូវ ដើម្បីពង្រីកអាជីវកម្ម និងគ្រប់គ្រងលំហូរសាច់ប្រាក់របស់ពួកគាត់ ដែលអាចផ្តល់អត្ថប្រយោជន៍ច្រើនសម្រាប់ការអភិវឌ្ឍន៍របស់ពួកគាត់ ក៏ដូចជាការបង្កើតការងារដល់ប្រជាជនកម្ពុជាផងដែរ។

For the bank, CGCC helps increase loan portfolios by providing guarantees for potential borrowers who do not have collateral, reducing credit risk by 70%-80%. For borrowers, they can get loans at cheaper rates and good advice on how to use loans responsibly to grow their businesses and improve their cash flow, which is very beneficial for their development and helps create jobs for Cambodian people.

៣. តើកន្លងមក ធនាគារ ហ្វីលីព បានប្រើប្រាស់ការធានាឥណទាន ដើម្បីផ្តល់កម្ចីប្រភេទណា?

So far, which type of loans does PhillipBank use the credit guarantees to support?

កន្លងមកធនាគារ ហ្វីលីព បានប្រើប្រាស់ការធានាឥណទាន ដើម្បីផ្តល់កម្ចីដូចជាកម្ចីមានកាលកំណត់ (TL) និង Overdraft (OD) ដែលគ្របដណ្តប់លើអាជីវកម្មខ្នាតមីក្រូ តូច និងមធ្យម (MSME)។

There are Term loan (TL) and Overdraft (OD), covering Micro, Corporate, MSME, and SME.

៤. តើម្ចាស់អាជីវកម្ម គួររៀបចំខ្លួនយ៉ាងដូចម្តេច ដើម្បីទទួលបានកម្ចីដែលមានការធានាពី ហ្វីលីព?

How should the borrowers prepare themselves in order to get guaranteed loans from PhillipBank?

អ្នកខ្ចីត្រូវតែជានីតិបុគ្គលដែលត្រូវបានចុះបញ្ជីត្រឹមត្រូវក្នុងប្រទេសកម្ពុជា ជនជាតិខ្មែរ ឬក្រុមហ៊ុនមានភាគហ៊ុនលើសពី 50% ជារបស់ខ្មែរ។ ដំណើរការអាជីវកម្មរបស់ពួកគេគួរតែល្អ និងបង្ហាញពីនិន្នាការប្រសើរឡើងជាបន្តបន្ទាប់ ជាពិសេសកំណត់ត្រាការទូទាត់សងរបស់ពួកគេជាមួយធនាគារផ្សេងទៀត (ប្រសិនបើមាន) ដែលអាចបង្ហាញពីការប្តេជ្ញាចិត្ត និងការទទួលខុសត្រូវបំណុលរបស់ពួកគេ។ ជាចុងក្រោយ ការស្នើសុំកម្ចី គួរតែមានគោលបំណងច្បាស់លាស់ និងសមស្រប។

Borrowers must be legal entities that are duly registered in Cambodia, Cambodian nationals, or Cambodian-owned businesses. Their business performance should be good and show a consistent improvement trend over time, especially their prompt payment record with other banks (if any), which could demonstrate their commitment and debt responsibility. Finally, the proposal should have a clear and appropriate purpose.

៥. តើធនាគារ ហ្វីលីព មានយុទ្ធសាស្ត្រ ឬផែនការដូចម្តេច ដើម្បីបន្តបង្កើនការបញ្ចេញកម្ចីដែលមានការធានាក្នុងឆ្នាំ២០២៤ ខាងមុខ?

What is the PhillipBank strategy/plan to further expand the disbursement of guaranteed loans in 2024?

យើងមានបំណងគាំទ្រម្ចាស់អាជីវកម្មដែលមានសក្តានុពល ជាពិសេស MSMEs និង SME ដែលមានសមត្ថភាពហិរញ្ញវត្ថុរឹងមាំក្នុងការសងត្រឡប់ ប៉ុន្តែខ្វះទ្រព្យធានា។យើងនឹងផ្សព្វផ្សាយបន្ថែមអំពីគ្រោងធានាព័ណទាន។ យើងមានសាខានៅតាមបណ្តាខេត្តភាគច្រើនក្នុងប្រទេសកម្ពុជា ដែលយើងអាចពិនិត្យ និងស្វែងរកអតិថិជនល្អ ដើម្បីផ្តល់ហិរញ្ញប្បទានដល់ពួកគាត់តាមរយៈ CGCC។ យើងនឹងជួយឱ្យពួកគាត់ពង្រីកអាជីវកម្មរបស់ពួកគាត់ ដើម្បីបង្កើនប្រាក់ចំណូលបន្ថែម និងរួមចំណែកដល់កំណើនសេដ្ឋកិច្ច ដោយវិធីសាស្ត្រដូមីណូ។

We aim to support potential borrowers, especially in the MSMEs that have strong financial ability to repay the loan but lack collateral. We will promote more about the scheme. We have branches in most of the provinces in Cambodia, where we can screen and scan for good customers and finance them through CGCC. This will help them expand their businesses to generate more income and contribute to economic growth by the domino method.

ការស្វែងយល់ពីការធានាលើសញ្ញាប័ណ្ណ | Understanding CGCC's Bond Guarantee

ដោយ៖ លោក ណូ លីដា អគ្គនាយករង

KH នៅខែមេសា ឆ្នាំ២០២២ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានកំណត់គោលដៅយុទ្ធសាស្ត្រឱ្យ CGCC ធ្វើពិពិធកម្មសេវាធានាឥណទាន ទៅកាន់ការធានាឥណទានលើការបោះផ្សាយសញ្ញាប័ណ្ណ។ CGCC បានរៀបចំខ្លួននិងត្រូវបានទទួលស្គាល់ដោយនិយ័តករមូលបត្រកម្ពុជា (ន.ម.ក.) ជាបុគ្គលធានាលើការបោះផ្សាយសញ្ញាប័ណ្ណក្នុងស្រុក ក្នុងខែសីហា ឆ្នាំ២០២៣ និងបានបញ្ចប់នីតិវិធីវាយតម្លៃលទ្ធភាពសង ដោយទទួលបានចំណាត់ថ្នាក់ឥណទាន **"khAAA"** (Outlook: Stable) ដែលជាចំណាត់ថ្នាក់ខ្ពស់បំផុតក្នុងស្រុក ពីក្រុមហ៊ុន រ៉េតធីង អេជេនស៊ី អហ្វ ខេបូឌា។ ជាមួយលក្ខខណ្ឌទាំងអស់នេះ CGCC នឹងចាប់ផ្តើមបេសកកម្មថ្មី ក្នុងការផ្តល់ការធានាឥណទានលើការបោះផ្សាយសញ្ញាប័ណ្ណ ដើម្បីចូលរួមជំរុញការអភិវឌ្ឍទីផ្សារទុននៅកម្ពុជា និងគាំទ្រសហគ្រាសខ្នាតតូច និងមធ្យម (SMEs) ដែលមានបំណងកៀរគរទុន នៅក្នុងទីផ្សារសញ្ញាប័ណ្ណ។

តើអ្វីទៅជាសញ្ញាប័ណ្ណ?

សញ្ញាប័ណ្ណ ឬមូលបត្របំណុល គឺជាប្រភេទកម្ចីដែលអាចជំនួសឱ្យកម្ចីធនាគារ។ អ្នកបោះផ្សាយសញ្ញាប័ណ្ណ គឺជាអ្នកខ្ចី រីឯអ្នកវិនិយោគលើសញ្ញាប័ណ្ណគឺជាអ្នកផ្តល់កម្ចី។ អ្នកវិនិយោគលើសញ្ញាប័ណ្ណ ទិញសញ្ញាប័ណ្ណពីអ្នកបោះផ្សាយ ដែលសន្យាទូទាត់ការប្រាក់ (គូប៉ុង) និងប្រាក់ដើម ជូនអ្នកទិញសញ្ញាប័ណ្ណ ក្នុងអំឡុងពេលឥណប្រតិទានៃសញ្ញាប័ណ្ណ។ សញ្ញាប័ណ្ណ មានភាពបត់បែនជាងកម្ចីធនាគារ ទៅលើលក្ខខណ្ឌ, ទំហំ, ឥណប្រតិទាន, និងអត្រាការប្រាក់។

ជាទូទៅ SME និងឯកត្តបុគ្គលណាក៏អាចកៀរគរទុន តាមរយៈកម្ចីធនាគារបានដែរ ឱ្យតែមានលទ្ធភាពសងគ្រប់គ្រាន់ ប៉ុន្តែមានតែ SME ដែលមានអភិបាលកិច្ច និងប្រតិបត្តិការអាជីវកម្មល្អ, របាយការណ៍ហិរញ្ញវត្ថុស្តង់ដារ និងអាចជឿទុកចិត្តបាន, ព្រមទាំងផែនការអាជីវកម្មរឹងមាំប៉ុណ្ណោះ ដែលអាចកៀរគរទុន តាមរយៈការបោះផ្សាយសញ្ញាប័ណ្ណបាន។ និយាយឱ្យខ្លី លក្ខខណ្ឌសម្រាប់ការបោះផ្សាយសញ្ញាប័ណ្ណមានភាពស្មុគស្មាញ និងតឹងតែងជាងលក្ខខណ្ឌសម្រាប់ស្នើសុំកម្ចីពីធនាគារ។ តារាងខាងក្រោម បង្ហាញពីការប្រៀបធៀបចំណុចសំខាន់ៗ រវាងកម្ចីធនាគារ និងសញ្ញាប័ណ្ណ។

ចំណុចសំខាន់ៗ	កម្ចីធនាគារ	សញ្ញាប័ណ្ណ
ទំហំ និងឥណប្រតិទាន	ភាគច្រើន មានរយៈពេលខ្លី និងទំហំតូចជាងសញ្ញាប័ណ្ណ	អាចមានទំហំធំជាង និងរយៈពេលវែងជាងកម្ចីធនាគារ
ការប្រាក់	ភាគច្រើន ខ្ពស់ជាងអត្រាការប្រាក់ (គូប៉ុង) របស់សញ្ញាប័ណ្ណ	មានភាពបត់បែន (អាចថេរ, អាចប្រែប្រួល, អាចមាន, ឬអាចមិនមានការប្រាក់)
ការជួញដូរ	មិនអាចជួញដូរបាន	ជាទូទៅ សញ្ញាប័ណ្ណអាចត្រូវបានជួញដូរលើទីផ្សារបន្ទាប់ មានន័យថាប្រសិនយើងមានសញ្ញាប័ណ្ណ យើងអាចលក់សញ្ញាប័ណ្ណនោះទៅអ្នកផ្សេង មុនពេលផុតឥណប្រតិទានរបស់សញ្ញាប័ណ្ណនោះ។
អ្នកផ្តល់កម្ចី	ស្ថាប័នហិរញ្ញវត្ថុតែមួយ ដែលជាធនាគារ ឬគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ	វិនិយោគិនច្រើនរួមគ្នា ដូចជាក្រុមហ៊ុនធានារ៉ាប់រង, ធនាគារ និងក្រុមហ៊ុនសោធន ជាដើម។
អ្នកខ្ចី	ឯកត្តបុគ្គល ឬក្រុមហ៊ុនអាជីវកម្ម	រាជរដ្ឋាភិបាល ឬក្រុមហ៊ុនអាជីវកម្ម
លក្ខខណ្ឌផ្សេងៗ	ជាទូទៅ ធនាគារ/គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជាអ្នកកំណត់លក្ខខណ្ឌនៃកម្ចី។	អ្នកបោះផ្សាយ (អ្នកខ្ចី) កំណត់លក្ខខណ្ឌនៃសញ្ញាប័ណ្ណ។

ពិតណាស់ ការបោះផ្សាយសញ្ញាប័ណ្ណ គឺជាវិធីសាស្ត្រសាមញ្ញសម្រាប់រដ្ឋាភិបាល និងក្រុមហ៊ុនអាជីវកម្ម ដើម្បីកៀរគរទុន នៅតាមបណ្តាប្រទេសអភិវឌ្ឍន៍ជាច្រើន ដើម្បីគាំទ្រគម្រោងនានា ប៉ុន្តែវិធីសាស្ត្រនេះមិនទាន់ត្រូវបានប្រើប្រាស់បានទូលំទូលាយនៅឡើយទេនៅកម្ពុជា។ ទីផ្សារសញ្ញាប័ណ្ណនៅកម្ពុជា ស្ថិតនៅក្នុងដំណាក់កាលកំពុងអភិវឌ្ឍន៍នៅឡើយ ដោយមានបញ្ហាប្រឈមសំខាន់ៗដូចជា សន្ទនីយភាពទាប, អត្រាការប្រាក់ខ្ពស់, និងមូលដ្ឋានវិនិយោគិនតូចចង្អៀតជាដើម។ ប៉ុន្តែយើងឃើញមានវឌ្ឍនភាពជាវិជ្ជមានជាច្រើនក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ជាពិសេសការចាប់ផ្តើមបោះផ្សាយសញ្ញាប័ណ្ណរដ្ឋ, សញ្ញាប័ណ្ណដែលមានការធានា, និងសញ្ញាប័ណ្ណនិរន្តរភាព។ បច្ចុប្បន្នមានសញ្ញាប័ណ្ណសាជីវកម្មចំនួន៩ បានចុះបញ្ជីនៅលើក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា (CSX) ដែលបានកៀរគរទុនចន្លោះពី ១,៥លានដល់ ៣០លានដុល្លារ ពីការបោះផ្សាយនីមួយៗ។

តើអ្វីជាការធានាលើការបោះផ្សាយសញ្ញាប័ណ្ណ?

ហានិភ័យធំបំផុតដែលវិនិយោគិនសញ្ញាប័ណ្ណជួបប្រទះ គឺការក្ស័យធនរបស់អ្នកបោះផ្សាយ នៅពេលអ្នកបោះផ្សាយមិនអាចធ្វើការទូទាត់ត្រឡប់ទៅឱ្យវិនិយោគិនវិញ។ ដូច្នេះហើយទើបមានតម្រូវការនៃការធានាលើការបោះផ្សាយសញ្ញាប័ណ្ណ។ អ្នកធានាលើការបោះផ្សាយសញ្ញាប័ណ្ណផ្តល់ការធានា ដោយសន្យាធ្វើការទូទាត់ជូនទៅវិនិយោគិនសញ្ញាប័ណ្ណ ប្រសិនបើអ្នកបោះផ្សាយសញ្ញាប័ណ្ណមិនមានលទ្ធភាពទូទាត់។ ផ្អែកលើនិយមន័យដែលកំណត់ដោយ ន.ម.ក. សញ្ញាប័ណ្ណមានបុគ្គលធានា សំដៅដល់សញ្ញាប័ណ្ណដែលផ្តល់ការធានាថាការប្រាក់និងប្រាក់ដើម នឹងត្រូវបានទូទាត់សងដោយភាគីទីបី ដែលជានីតិបុគ្គល ករណីដែលបុគ្គលបោះផ្សាយមិនមានលទ្ធភាពសងបំណុល (Default) ដោយមូលហេតុដូចជា អសាធនភាព ឬក្ស័យធន។ ក្រាហ្វិកទី១ ពន្យល់ពីដំណើរការនៃការធានាលើសញ្ញាប័ណ្ណ។ ក្រាហ្វិកទី២ ពន្យល់ពីដំណើរការនៃការសងត្រឡប់ក្នុងករណីអ្នកបោះផ្សាយសញ្ញាប័ណ្ណដែលមានបុគ្គលធានាអសាធនភាព ឬក្ស័យធន។

ក្របខ័ណ្ឌគោលនយោបាយ នៃការធានាលើបោះផ្សាយសញ្ញាប័ណ្ណរបស់ CGCC ត្រូវបានអនុម័តដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុក្នុងខែឧសភា ឆ្នាំ២០២៣ ជាទិសដៅគោលនយោបាយសម្រាប់ CGCC ក្នុងការធានាលើការបោះផ្សាយសញ្ញាប័ណ្ណ។ ផ្អែកលើក្របខ័ណ្ឌគោលនយោបាយនេះ រាល់សញ្ញាប័ណ្ណដែលធានាដោយ CGCC ត្រូវចុះបញ្ជីលើក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា (CSX) និងត្រូវជាសញ្ញាប័ណ្ណដែលត្រូវបានបោះផ្សាយជាលុយរៀល។ ស្របតាមឧត្តមានុវត្តន៍ជាអន្តរជាតិ ការធានាលើសញ្ញាប័ណ្ណរបស់ CGCC មិនអាចលុបចោល និងមិនមានលក្ខខណ្ឌ។ មានន័យថា បន្ទាប់ពី CGCC អនុម័តការធានាលើសញ្ញាប័ណ្ណណាមួយ ការធានានោះមិនអាចលុបចោលវិញបានទេ ហើយ CGCC ត្រូវតែទូទាត់សងជំនួសអ្នកបោះផ្សាយសញ្ញាប័ណ្ណដោយឥតលក្ខខណ្ឌ ក្នុងករណីអ្នកបោះផ្សាយមិនមានលទ្ធភាពទូទាត់សងទៅឱ្យវិនិយោគិន។ CGCC បានកំណត់ទំហំសញ្ញាប័ណ្ណដែលត្រូវផ្តល់ការធានាត្រឹម ២០លានដុល្លារ និងឥណប្រតិទានត្រឹម ១០ឆ្នាំ។ បន្ថែមពីនេះ កម្រៃធានាឥណទាន នឹងត្រូវកំណត់ដោយផ្អែកលកម្រិតហានិភ័យនៃសញ្ញាបណ្ណ។ ដោយសារបទពិសោធន៍ និងសមត្ថភាពមានកម្រិត CGCC នឹងផ្តល់ការធានាលើសញ្ញាប័ណ្ណ ដោយសហការជាមួយក្រុមហ៊ុនធានាឥណទានអន្តរជាតិដែលមានបទពិសោធន៍ តាមរយៈការធានារួមគ្នា ឬការធានាបន្ត ឬការសហការផ្សេងៗទៀត តាមដែលអាចធ្វើបាន ដើម្បីអភិវឌ្ឍសមត្ថភាពនិងប្រើប្រាស់ជំនាញអំពីទីផ្សារក្នុងស្រុក ដើម្បីគាំទ្រដល់ការអភិវឌ្ឍទីផ្សារទុននៅកម្ពុជា។

ការធានាលើសញ្ញាប័ណ្ណអាចដើរតួយ៉ាងសំខាន់ ក្នុងការគាំទ្រ SMEs និងសហគ្រាសខ្នាតធំ ឱ្យបោះផ្សាយសញ្ញាប័ណ្ណដើម្បីកៀរគរទុន តាមរយៈការជួយលើកកម្ពស់លទ្ធភាពសងរបស់សញ្ញាប័ណ្ណ និងទំនុកចិត្តរបស់វិនិយោគិនមកលើសញ្ញាប័ណ្ណដែលមានបុគ្គលធានា ដែលអាចជំរុញការវិនិយោគលើសញ្ញាប័ណ្ណ។ ជារួមការធានាលើសញ្ញាប័ណ្ណនឹងគាំទ្រដល់ការអភិវឌ្ឍទីផ្សារសញ្ញាប័ណ្ណនៅកម្ពុជា។

Chart 1: Bond Guarantee



Chart 2: Claim Payment



*The above structure are simplified for understanding only. The structure of the actual case may vary.

Understanding CGCC's Bond Guarantee

By: Mr. No Lida, Deputy Chief Executive Office

EN In April 2022, the Ministry of Economy and Finance provided a policy direction to CGCC to diversify our guarantee service to bond guarantees. CGCC was then accredited by the Securities and Exchange Regulator of Cambodia (SERC) in August 2023 as a local bond guarantor and completed its rating procedure, and was rated "***khAAA***" with a Stable Outlook, the highest rating on a local scale by the Rating Agency of Cambodia. With all these set, CGCC will embark on a new journey to provide guarantees on bond issuance to support Cambodia's capital market and the small and medium enterprises (SMEs) looking to enter the bond market for their sources of funding.

What is a bond?

A bond is a debt instrument, one of the alternatives to a bank loan. The bond issuer is a borrower, and the bond investor is a lender. Bond investors buy bonds from the issuer, who promises to pay interest (coupons) and bond principal during the bond maturity. Compared to a bank loan, a bond gives more flexibility in terms of structure, size, maturity, and interest payment. While just about any SME and individual can raise funds with bank loans as long as they can prove their repayment capacity, raising funds with bonds requires the issuer to be a more well-established and matured SME that can demonstrate good governance and business operation, reliable financial records, concrete future business plan and so on. In short, compared to bank loans, the requirements to issue bonds are stricter and more extensive. The table below gives a brief general comparison between a bank loan and a bond.

Indeed, issuing bonds is a common way for Governments and businesses to raise capital in many developed countries to finance their projects. It is not yet so much so in Cambodia. The bond market in Cambodia is still in the developing stage, facing challenges such as low liquidity, high-interest rates, and a low investor base. However, we have seen positive breakthroughs in recent years, especially in the issuance of government bonds, guaranteed bonds, and sustainable bonds. Currently, there are 9 listed corporate bonds on the Cambodia Securities Exchange (CSX) raising funds between 1.5 to 30 million USD equivalent per issuance.

What is a bond guarantee?

The major risk that bond investors face is the default of the issuer when the issuer cannot repay bond investors. It is when the bond guarantor comes in. The bond guarantor provides guarantees on the bond by promising to make repayments to bond investors if the bond issuer defaults. According to SERC's definition, a guaranteed bond refers to a bond that guarantees interests and principal payment by a third party in case the issuers default for a reason, such as insolvency or bankruptcy. Chart 1 illustrates the flow of CGCC's bond guarantee and chart 2 illustrates the flow of claim payment of CGCC's guaranteed bond when the issuer defaults.

CGCC's bond guarantee policy framework was approved by the Ministry of Economy and Finance in May 2023 as a policy direction and guidance on how CGCC should provide guarantees on bonds. Based on the policy framework, all CGCC's guaranteed bonds must be listed on the Cambodia Securities Exchange (CSX) and shall be denominated in the local currency, Khmer Riel. Following the best practices, CGCC's bond guarantee is unconditional and irrevocable, meaning that CGCC shall not call off the guarantee once it is approved and shall honor the claims without conditions. CGCC caps the guaranteed bond size at 20 million USD equivalent and the bond maturity at 10 years. Moreover, the guarantee fee will be based on the risk of the bond, risk-based pricing. Due to lacking experience and resources, CGCC will approach the bond guarantees by working with experienced international bond guarantors through co-guarantees or re-guarantees and other feasible business collaborations to develop its capacity and leverage its local expertise to support the local capital market development.

Bond guarantees can play a significant role in supporting SMEs and large firms in issuing bonds to raise capital by helping improve the creditworthiness of the bond, hence increasing investors' confidence and investment in the bonds. Overall, it will support the development of the bond market in Cambodia.

Key Elements	Bank Loan	Bond
Size & Tenure	In most cases, shorter tenure, and a smaller size than a bond.	It can be substantially larger in size and have a longer tenure than a bank loan.
Interest Rate	In most cases, higher than the bond's coupon rate.	More Flexible. It can be fixed, variable, with or without interest (coupon) payment.
Trading	Non-tradable	In theory, bonds can be traded on the secondary market, meaning if you have a bond, you can sell it to someone else before the bond maturity.
Lender	A single financial institution such as a bank/microfinance institution	Multiple investors, such as insurance companies, banks, pension funds, etc.
Borrower	Individual and business	Government and business
Other Terms and Conditions	Generally, banks/Microfinance Institutions (lenders) set the terms and conditions of the loans.	The issuer (borrowers) sets the terms and conditions of the bond.

ជួបជាមួយម្ចាស់អាជីវកម្មដែលទទួលបានកម្ចីដែលមានការធានាពី CGCC | Meet the Business Owner Who Received a Loan Guaranteed by CGCC

លោកស្រី ខៀវ ធិតា ស្ថាបនិក SOGE Green Solar Energy | Ms. Kheav Thida, Founder of SOGE Green Solar Energy Cambodia

KH Solar Green Energy (SOGE) គឺជាក្រុមហ៊ុនផ្តត់ផ្គង់ថាមពលបៃតង ដោយប្រើប្រាស់ថាមពលនៃពន្លឺព្រះអាទិត្យ ដើម្បីស្រូបយកទឹកទន្លេធម្មជាតិ សម្រាប់ការស្រោចស្រស់ដំណាំរបស់ប្រជាកសិករខ្មែរ ដែលត្រូវបានបង្កើតឡើងក្នុងឆ្នាំ ២០០៨។ បន្ទាប់ពីចាប់ផ្តើមដំណើរការបានមួយរយៈ អតិថិជនចាប់ផ្តើមស្គាល់ក្រុមហ៊ុន និងចាប់ផ្តើមផ្តល់ការជឿទុកចិត្តលើសេវាកម្មរបស់ពួកយើង។ នាងខ្ញុំបានមើលឃើញពីឱកាស ក្នុងការពង្រីកអាជីវកម្មនេះឱ្យកាន់តែធំ។ ពួកយើងមានបច្ចេកវិទ្យាគ្រប់គ្រាន់ ប៉ុន្តែខ្វះធនធានមនុស្ស និងទុនបន្ថែម។

នាងខ្ញុំបានប្រឹក្សាជាមួយធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមួយចំនួន ដើម្បីទទួលបានទុនបន្ថែម។ ដោយសារនាងខ្ញុំខ្វះទ្រព្យធានា ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ ក៏បានណែនាំនាងខ្ញុំ អំពីការធានាឥណទានលើកម្ចីអាជីវកម្មរបស់ CGCC ដែលអាចផ្តល់ការធានាលើកម្ចីរបស់នាងខ្ញុំ ដើម្បីឱ្យធនាគារអាចផ្តល់កម្ចីដល់នាងខ្ញុំបាន ទោះបីគ្មានទ្រព្យធានា។ ដោយសារការធានាឥណទានពី CGCC នាងខ្ញុំអាចទទួលបានទុនបន្ថែម ដើម្បីសាងសង់ស្ថានីយបូមទឹកថ្មីៗទៀតបន្ថែម។

SOGE បានប្រើប្រាស់កម្ចីដែលមានដែលការធានាពី CGCC ដើម្បីពង្រីកការសាងសង់ស្ថានីយ៍បូមទឹក នៅតាមបណ្តាខេត្ត មួយចំនួនដូចជា ខេត្តពោធិ៍សាត់ ខេត្តកំពង់ចាម ខេត្តកំពង់ឆ្នាំង ខេត្តកំពង់ធំ។ ស្ថានីយ៍ទាំងអស់នោះ អាចស្រោចស្រពូវផ្ទៃដីប្រម៉ាណ ១៦០០ ហិកតា និងបានផ្តល់អត្ថប្រយោជន៍ដល់ប្រជាជនប្រមាណ ១០០០ គ្រួសារ។

នាងខ្ញុំយល់ថា ការធានាឥណទានរបស់ CGCC ពិតជាអាចគាំទ្រដល់អាជីវកម្មរបស់នាងខ្ញុំ ក៏ដូចជាសហគ្រាសខ្នាតតូច និងមធ្យមផ្សេងទៀត ដែលមានសក្តានុពល ប៉ុន្តែខ្វះទ្រព្យធានា ឱ្យទទួលបានទុនបន្ថែមចាំបាច់ពីធនាគារ ឬគ្រឹះស្ថានហិរញ្ញវត្ថុ សម្រាប់ការពង្រីកអាជីវកម្ម។៖

EN Solar Green Energy (SOGE), established in 2008, is a company providing green energy solutions using solar energy to irrigate the crops of Cambodian farmers. Shortly after the establishment, customers began to recognize SOGE and trust our services. I saw the opportunity to expand our business. We have the technology but lack human resources and capital.

I consulted with some banks and microfinance institutions to get additional capital. Because I didn't have enough collateral for the loans, J Trust Royal Bank introduced me CGCC's credit guarantee service which can guarantee my loan so that the bank can lend me without requiring my collateral. With the credit guarantee, I could get additional capital to build new pumping stations.

SOGE used the loans guaranteed by CGCC to expand the construction of pumping stations in some provinces such as Pursat, Kampong Cham, Kampong Chhnang and Kampong Thom. The stations can irrigate about 1,600 hectares and benefit about 1,000 families.

I think that CGCC's credit guarantees can really support my business as well as other potential SMEs that lack collateral to get necessary capital from banks or microfinance institutions for their business expansion.

មូលនិធិធានាប្រាក់បញ្ញើសន្សំ និងឥណទាន នៃប្រទេសនេប៉ាល់ (DCGF) | Deposit And Credit Guarantee Fund (DCGF) of Nepal

ដោយ៖ លោក គី ហុង បុគ្គលិកជំនាញផ្នែកអភិវឌ្ឍផលិតផល | By: Mr. Ky Hong, Executive of Product Development



KH មូលនិធិធានាប្រាក់បញ្ញើ និងឥណទាននៃប្រទេសនេប៉ាល់ (DCGF) ត្រូវបានបង្កើតឡើងនៅថ្ងៃទី២០ ខែកញ្ញា ឆ្នាំ១៩៧៤ ក្រោមការផ្តួចផ្តើម និងផ្តល់ដើមទុនដំបូងពីធនាគារកណ្តាលរបស់នេប៉ាល់ ធនាគាររ៉ាស្ត្រីយ៉ា ប៉ានីយ៉ា (Rastriya Benijya Bank) និងធនាគារនេប៉ាល់លីមីតធីត (Nepal Bank Limited)។ គោលបំណងនៃការបង្កើត (DCGF) គឺដើម្បីធានាលើប្រាក់បញ្ញើ ការពារសុខុមាលភាពសេដ្ឋកិច្ចរបស់សាធារណជនទូទៅ និងលើកកម្ពស់លទ្ធភាពទទួលបានឥណទានពីស្ថាប័នហិរញ្ញវត្ថុ។

គិតត្រឹមឆ្នាំ២០២៣ (DCGF) មានដើមទុនចំនួន ១០ ពាន់លាន NPR (ប្រមាណ ៧៥លានដុល្លារ) ដែលក្នុងនោះ ៩ពាន់លាន NPR (ស្មើនឹង ៦៧.៥លានដុល្លា) បានមកពីរដ្ឋាភិបាលនៃប្រទេសនេប៉ាល់ និងចំនួន ១ពាន់លាន NPR ទៀត (ស្មើនឹង ៧.៥លានដុល្លា) បានមកពីធនាគារកណ្តាលនៃប្រទេសនេប៉ាល់ (Nepal Rastra Bank)។ គិតត្រឹមឆ្នាំ២០២៣ ទំហំសរុបនៃការធានាលើកម្ចី មានប្រមាណជាង ២ប៊ីលានដុល្លា ហើយទំហំសរុបនៃការធានាលើប្រាក់បញ្ញើ មានប្រមាណជាង ៩.២ប៊ីលានដុល្លា។

DCGF ផ្តល់នូវសេវាធានាចំនួន២ប្រភេទ គឺសេវាក្នុងការធានាប្រាក់បញ្ញើសន្សំ (Deposit Guarantee) និងសេវាក្នុងការធានាឥណទាន (Credit Guarantee) ។

១ ការធានាលើប្រាក់បញ្ញើ (Deposit Guarantee)៖ ផ្តល់ការធានាលើប្រាក់បញ្ញើរបស់អ្នកដាក់ប្រាក់បញ្ញើ ដោយទូទាត់សងត្រឡប់ជូនទៅអ្នកដាក់ប្រាក់បញ្ញើ ក្នុងករណីស្ថាប័នហិរញ្ញវត្ថុដែលទទួលប្រាក់បញ្ញើនោះក្ស័យធន។

២ ការធានាឥណទាន (Credit Guarantee): DCGF បានដាក់ចេញនូវគម្រោងធានាឥណទានចំនួន ៧ រួមមាន៖

១) ការធានាឥណទានលើវិស័យចិញ្ចឹមសត្ត (Livestock Guarantee)

២) ការធានាឥណទានសម្រាប់សហគ្រាសធុនតូច និងមធ្យម (SME Credit Guarantee)

៣) ការធានាឥណទានលើវិស័យកសិកម្ម (Agriculture Credit Guarantee)

៤) ការធានាឥណទានលើវិស័យមីក្រូហិរញ្ញវត្ថុ និងវិស័យដែលត្រូវយកចិត្តទុកដាក់ (Microfinance and Deprived Sector Credit Guarantee)

៥) ការធានាលើកម្ចីសម្រាប់ការអប់រំ និងសម្រាប់អភិវឌ្ឍន៍ជំនាញដល់អ្នកគ្មានការងារធ្វើ (Educational loan and Educational Unemployed Business Credit Guarantee)

៦) ការធានាឥណទានលើកម្ចីឧបត្ថម្ភធន (Subsidy Loan Guarantee)

៧) ការធានាឥណទានលើកម្ចីសម្រាប់ការនាំចេញ (Export Credit Guarantee)។

EN Deposit And Credit Guarantee Fund (DCGF) of Nepal was established on 20th September 1974 under the initiation and equity participation of Central Bank of Nepal, Rastriya Banijya Bank, and Nepal Bank Limited. The main objective of DCGF is to secure public deposits and institutional credits, safeguard and conserve the economic well-being of the general public, and promote access to institutional credits.

As of 2023, the authorized Capital of the fund has been increased to 10 billion NPR (equivalent to USD 75 million) where 9 billion NPR (equivalent to USD 67.5 million) comes from the Government of Nepal and 1 billion (equivalent to 7.5 million) comes from Central Bank (Nepal Rastra Bank). As of 2022/2023, the total credit risk guaranteed amounts to 2 billion USD, and the total deposit risk guaranteed amounts to 9.2 billion USD.

DCGF offers two main guarantee services including Deposit Guarantee and Credit Guarantee.

1 Deposit Guarantee: To guarantee the deposit of depositors and to compensate the loss to the depositor in case of legitimate bankruptcy of the member institution.

2 Credit Guarantee: DCGF provides 7 credit guarantee products including

1) Livestock guarantee

2) SME Credit Guarantee

3) Agriculture Credit Guarantee

4) Microfinance and Deprived Sector Credit Guarantee

5) Educational loan and Educational Unemployed Business Credit Guarantee

6) Subsidy Loan Guarantee

7) Export Credit Guarantee.

Source: 31st ACSIC Training Material

CGCC នៅលើសារព័ត៌មាននានា | CGCC on the News

CGCC និងសាខាធនាគារកសិកន ផាប់ប្ជ្ជីក ខមភេនី លីមីធីត ចុះកិច្ចព្រមព្រៀងធានាឥណទាន គាំទ្រការទទួលបានកម្ចីដែលមានការធានាដល់ SME នៅកម្ពុជា

អត្ថបទអានជាភាសាខ្មែរ៖ Fresh News, Published on 02 October 2023

CGCC and Kasikornbank Agreement Inked to Support Cambodian MSMEs

News article in English from: The Phnom Penh Post, Published on 02 October 2023 & Khmer Times, Publish on 03 October 2023

CGCC Provides $149M Credit Support

News article in English from: Khmer Times, Published on 19 October 2023

$150M in Loans Guaranteed for SMEs by CGCC

News article in English from: The Phnom Penh Post, Published on 25 December 2023

ដៃគូរបស់យើង | Our Partners

ផលិតផលឥណទានដែលមានការធានាពី CGCC របស់ PFIs | Guarantee Product from Our PFIs

ផលិតផលឥណទាន ស្គារអាជីវកម្ម (CAMMA MFI)

ផលិតផលឥណទានស្គារអាជីវកម្ម ជាប្រភេទឥណទានមួយសម្រាប់បម្រើតម្រូវការ សហគ្រាសធុនតូច និងមធ្យម ដែលបង្កើតឡើងដោយអនុក្រឹត្យលេខ៖ ១៤០អនក្រ ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២០ ធ្វើប្រតិបត្តិការក្រោមការណែនាំបច្ចេកទេសពី សាជីវកម្មធានាឥណទានកម្ពុជា (CGCC) និងហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីធ្វើប្រតិបត្តិការលើវិស័យពាក់ព័ន្ធនឹងទុនបង្វិល និងទុនវិនិយោគ ដែលអតិថិជនមានគោលបំណងច្បាស់លាស់ក្នុងការវិនិយោគទៅក្នុងវិស័យអាទិភាព និងមិនមែនអាទិភាពដូចជា៖

- វិស័យកសិកម្ម៖ ដំណាំដាំដុះ ការចិញ្ចឹមសត្ត្ว រ៉ាវីវប្ផកម្ម
- វិស័យឧស្សាហកម្ម៖ ផលិតកម្ម និងកែច្នៃម្ហូបអាហារ ការផលិតទំនិញប្រើប្រាស់ក្នុងតំបន់ ការកែច្នៃកាកសំណល់ទៅជាផលិតផលសម្រាប់វិស័យទេសចរណ៍ ការផលិតគ្រឿងបន្លាស់ ឬគ្រឿងបង្គំផ្សេងៗ និងការផលិតផលិតផលឱសថដូចជា ឧបករណ៍ ឬថ្នាំពេទ្យ
- ផ្នែកសេវាកម្ម និងវិស័យមិនមែនអាទិភាព៖ ការផ្តល់សេវាកម្មបែបបច្ចេកវិទ្យា សេវាកម្មផ្នែកទេសចរណ៍ (ផ្ទះសំណាក់ សណ្ឋាគារ ភោជនីយដ្ឋាន និងភ្នាក់ងារធ្វើដំណើរ) សេវាកម្មដឹកជញ្ជូន និងការអប់រំ (ការបណ្តុះបណ្តាលវិជ្ជាជីវៈ និងការបណ្តុះបណ្តាលជំនាញទន់)

លក្ខណៈផលិតផល៖

- ទំហំឥណទាន ចាប់ពី ៣០.០០០ ដុល្លារ រហូតដល់ ៥០០.០០០ ដុល្លារ ឬសមមូលប្រាក់រៀល
- រយៈពេលឥណទាន រហូតដល់ ១២០ខែ
- ផ្តល់ជម្រើសងាយស្រួលក្នុងការបង់សងនៅតាមការិយាល័យ ខេមា ដែលនៅជិតបំផុត ឬតាមរយៈភ្នាក់ងារផ្សេងៗ ដែលជាដៃគូសហការរបស់ គ្រឹះស្ថាន ខេមា
- អត្រាការប្រាក់ថេរ ៦,៥% - ១៨% ក្នុងមួយឆ្នាំ និងគណនាការប្រាក់ទៅលើតែប្រាក់ដើមដែលកំពុងជំពាក់តែប៉ុណ្ណោះ
- របៀបបង់សងមានច្រើនជម្រើស ដូចជា៖
  - បង់សងប្រចាំខែទាំងប្រាក់ដើម និងការប្រាក់ថេរ
  - បង់សងប្រចាំខែទាំងប្រាក់ដើម និងការប្រាក់ថយចុះ
  - បង់តាមការចរចា

លក្ខខណ្ឌតម្រូវ៖

- មានអាយុចាប់ពី ១៨ឆ្នាំ ដល់ ៦៥ឆ្នាំ
- មានអត្តសញ្ញាណច្បាស់លាស់ជាជនជាតិខ្មែរ ឬនីតិបុគ្គលដែលមានទីលំនៅអចិន្ត្រៃយ៍ក្នុងតំបន់ប្រតិបត្តិការរបស់គ្រឹះស្ថាន ខេមា
- មានអាជីវកម្មស្របច្បាប់ ដែលបានចុះបញ្ជីត្រឹមត្រូវ និងអាជីវកម្មដែលមិនទាន់បានចុះបញ្ជីជាផ្លូវការ

របៀបដាក់ពាក្យស្នើសុំ៖

- ជួបជាមួយភ្នាក់ងារឥណទានរបស់ គ្រឹះស្ថាន ខេមា នៅក្នុងតំបន់របស់លោកអ្នក ឬអញ្ជើញទៅកាន់ សាខាគ្រឹះស្ថាន ខេមា ដែលនៅជិតលោកអ្នកបំផុត
- ទំនាក់ទំនងផ្នែកសេវាអតិថិជនតាមទូរស័ព្ទ៖
  ០១៧ ៩០៧ ៥៥៥ / ០៩៨ ៩០៧ ៥៥៥ ឬចូលទៅកាន់តំណភ្ជាប់៖
  https://www.camma.com.kh/km/apply-now-loan/
  ដើម្បីដាក់ពាក្យស្នើកម្ចីអនឡាញ ដោយពុំចាំបាច់អញ្ជើញមកកាន់ការិយាល័យផ្ទាល់។

PFIs របស់ CGCC ដែលបានស្នើសុំការធានាឥណទានកន្លងមក | Our Active PFIs

ACLEDA BANK
Tel: 023 998 777
Email: acledabank@acledabank.com.kh
Web: www.acledabank.com.kh

APD BANK ASIA-PACIFIC DEVELOPMENT BANK
Tel: 023 211 888
Email: ccc@apdbank.com.kh
Web: www.apdbank.com.kh

CAMBODIAN PUBLIC BANK
Tel: 023 428 100
Email: CustomerService@campubank.com.kh
Web: www.campubank.com.kh

CAB BANK CAMBODIA ASIA BANK
Tel: 023 980 000
Email: sale@cab.com.kh
Web: www.cab.com.kh

CAMBODIA POST BANK PLC.
Tel: 023 260 888
Email: info@cambodiapostbank.com
Web: www.cambodiapostbank.com

CANADIA BANK
Tel: 023 868 222
Email: contact@canadiabank.com.kh
Web: www.canadiabank.com.kh

CIMB BANK
Tel: 023 988 388
Email: customercare@cimb.com.kh
Web: www.cimbbank.com.kh

FTB Foreign Trade Bank of Cambodia
Tel: 023 862 111
Email: info@ftbbank.com
Web: www.ftbbank.com

Maybank
Tel: 098 888 028
Email: contactus.mcp@maybank.com
Web: www.maybank2u.com.kh

Oriental Bank
Tel: 023 932 288
Email: customerservice@orientalbank.com.kh
Web: www.orientalbank.com.kh

PhillipBank
Tel: 086 930 000
Email: info@phillipbank.com.kh
Web: www.phillipbank.com.kh

RHB
Tel: 023 992 833
Email: hello@rhbgroup.com
Web: www.rhbgroup.com.kh

SATHAPANA BANK
Tel: 023/081 992 010
Email: customercare@sathabana.com.kh
Web: www.sathapana.com.kh

ABA BANK NATIONAL BANK OF CANADA GROUP
Tel: 023 225 333
Email: info@ababank.com
Web: www.ababank.com

Amk
Tel: 023 220 202
Email: customerservice@amkcambodia.com
Web: www.amkcambodia.com

BRED BANK CAMBODIA
Tel: 1800 20 1234
Email: contact@bredcambodia.com
Web: www.bredcambodia.com

CAMMA MICROFINANCE
Tel: 023 533 9999
Email: info@camma.com.kh
Web: www.camma.com.kh

CHIP MONG BANK
Tel: 081 811 911
Email: info@chipmongbank.com
Web: www.chipmongbank.com/ en

ចម្រើន
Tel: 023 959 777
Email: info@chamroeun.com
Web: www.chamroeun.com

J Trust Royal Bank
Tel: 023 999 000
Email: ccc@jtrustroyal.com
Web: www.jtrustroyal.com

KASIKORNBANK
Tel: 023214 998
Email: kh_phnompenh@kasikornbank.com
Web: www.kasikornbank.com.kh

LOLC
Tel: 023 991 991
Email: info@lolc.com
Web: www.lolc.com.kh

PRINCE BANK
Tel: 1800-20-8888
Email: info@princebank.com.kh
Web: www.princebank.com.kh

Wing
Tel: 023 999 0989
Email: care.centre@wingmoney.com
Web: www.wingmoney.com

បើលោកអ្នកមានជាមតិយោបល់ដើម្បីកែលម្អ
ព្រឹត្តិបត្រព័ត៌មានរបស់ CGCC សូមទំនាក់ទំនង
មកក្រុមការងាររបស់យើងខ្ញុំតាមរយៈ
023 722 123 Info@cgcc.com.kh

បង្កើនបរិយាបន្នហិរញ្ញវត្ថុនិង អភិវឌ្ឍ សហគ្រាសខ្នាតតូច និងមធ្យម នៅកម្ពុជា

Improve Financial Inclusion and Develop SMEs in Cambodia

023 722 123
info@cgcc.com.kh
www.cgcc.com.kh
សាជីវកម្មធានាឥណទានកម្ពុជា
Credit Guarantee Corporation of Cambodia

សាជីវកម្មធានាឥណទានកម្ពុជា CGCC
Credit Guarantee Corporation of Cambodia (CGCC)
Business Development Center, 19th Floor, OCIC Blvd,
Sangkat Chroy Changvar, Khan Chroy Changvar,
Phnom Penh, Cambodia

www.cgcc.com.kh